ព្រះរាជបណ្ណាល័យកម្ពុជា

កម្ពុជសុរិយា

សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

ខ្សែ ១១

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវ៉ែរណើម៉ង់

គ្រិ. ឆ្នាំ ១៩២៨

ពុ. ស. ២៤៧១

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

បញ្ជីរឿង

ទំព័រ

១- ប្រវត្តិព្រះពុទ្ធរូបពុម្ព សាស្ត្រាចារ្យ សេដេស រៀបរៀងជាភាសាសៀម ព្រះស្នេហាសាទេព បណ្ឌិតនៅព្រះរាជបណ្ណាល័យ ប្រែជាភាសាខ្មែរ . ៣១៩

២- អំពីលំនាំដើមហេតុ នៃការដែលបានស្គាល់ប្រាសាទអង្គរ លោកវិគទ័រ-គោលូបែហ្វ អគ្គលេខាធិការ នៅសាលាបារាំងសែសនាចុងបូព៌ាប្រ-ទេស អធិប្បាយ ក្រមការ ជុំ-ម៉ៅ ប្រែចេញជាភាសាខ្មែរ . . . ៣២៨

៣- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជាឥន្ទ រៀបរៀង (ត) (អត្ថបទនេះ មិនមានចុះផ្សាយទេ ព្រោះមានបោះជាសៀវភៅហើយ)

៤- កោសជ ឬ សេចក្ដីខ្វល់ប្រអូសពាក្យកាព្យរបស់ ចឺ ឆ. គឹមហាក់ ធ្វើរាជការនៅក្នុងមន្ទីរប៉ុស្តិ៍ខ្សែលួសក្រុងភ្នំពេញ រៀបរៀង ៣៥០

៥- សេចក្ដីរាយការណ៍អំពីអ្នកតំណាងខេត្តកំពត នាំប្រាក់ចំនួន ១ ០០០៛ មកជូនព្រះរាជបណ្ណាល័យកម្ពុជា ក្រមការ ជុំ-ម៉ៅ ធ្វើរាជការក្នុងព្រះរាជ-បណ្ណាល័យ អធិប្បាយ ៣៥៩

ប្រវត្តិព្រះពុទ្ធរូបពុម្ព

សាស្ត្រាចារ្យ សេដេស រៀបរៀងជាភាសាសៀម

ព្រះស្នេហាសាទេព ក្រសេម

បណ្ឌិត នៅព្រះរាជបណ្ណាល័យ កម្ពុជា

ប្រែមកជាភាសាខ្មែរ

(២)

ព្រះពុម្ពដែលបានប្រទះក្នុងអាណាចក្រសៀម ចំណែកចែកចេញជាច្រើនពួកផងគ្នា តាមដែលបានស៊ើបសាវស្រាវរកបានសេចក្ដីមកអំពីព្រះរាជពង្សាវតារសៀម គឺ :

ពួកទី ១ បែបព្រះបឋម (ឱ្យមើលរូបទី ២.៧)[១] ដែលហៅដូចនេះ ក៏ព្រោះរបស់ប្រភេទនេះច្រើន តែបានមកអំពីបរិវេណព្រះបឋមចេតិយ មានលក្ខណៈដូចគ្នានឹងរូបឆ្លាក់ដែលបានប្រទះឃើញ នៅព្រះបឋមចេតិយ ព្រះពុម្ពនៅព្រះបឋមចេតិយច្រើនតែជារូបគ្រាមហាបាដិហារ្យ ព្រះពុម្ពនៅទីនោះជាន់ចាស់បំផុត ធ្វើឡើងប្រហែលជាកាលពុទ្ធសករាជ ៩៥០ ដល់ ១២៥០ គាថា យេ ធម្មា ។ ជាភាសាបាលី គេចារឹកដោយអក្សរគ្រឹន្ថ ឬជាអក្សរខមបុរាណ ។

ពួកទី ២ ព្រះពុទ្ធរូបបែបនៅគូហារមល្ងៃយូ (រូបទី ៧-៩) ព្រះពុទ្ធរូបបែបនេះសុទ្ធតែធ្វើដោយដីដុតស្ងួតតែទាំងអស់ ពីពុទ្ធសករាជប្រហែលជា

១- រូបទាំងនេះចាស់ពេក បើនឹងយកមកធ្វើពុម្ពឡើងវិញ មិនបាន ។

១៤៥០-១៩៥០ មានរូបពោធិសត្វខាងប៉ែកមហាយានផង គាថា យេធម្មា ដែលចារឹកជាភាសាសំស្ក្រឹតចារឹកដោយអក្សរនាគរី ដែលគេប្រើនៅក្នុងប្រទេសឥណ្ឌាប៉ែកលើ ។

ពួកទី ៣ បែបខ្មែរ (រូបទី ១០-១១) បែបនេះកើតឡើងរួមសម័យជាមួយគ្នា នឹងបែបនៅជ្រោយមលាយូ ឬថ្មីជាងគ្នាបន្តិចបន្តួច ដឹងបានដោយលក្ខណាការ និងគ្រឿងប្រដាប់ ដែលជារបស់ក្នុងលទ្ធិមហាយានជាមួយគ្នា ។

ពួកទី ៤ បែបសុខោទ័យ (រូបទី ១២-១៣) បែបនេះសាងប្រហែលជាក្នុងពុទ្ធសករាជ ១៧៥០-១៩៥០ ច្រើនតែជាក្នុងព្រះពុទ្ធរូបដើរ ឬដែលហៅថាព្រះលីលា ។

ពួកទី ៥ បែបអយុធ្យា (រូបទី ១៤-១៥) ជាបែបថ្មីមែនៗ តាម-ច្រើនមានព្រះពុទ្ធរូបមានកិរិយា និងឥរិយាបថតាមគ្រាផ្សេងៗ ។

ពួទី ៦ ព្រះគ្រឿងផ្សេងៗ បែបទី ១ ព្រះពុម្ពនៅបប់មចេតិយ មានប្លែកគ្នាជា ២ បែបដែលចាក់ជាស្នាដៃឥណ្ឌា ក្នុងរជ្ជសម័យនៃព្រះចៅ-គុប្ត (ប្រហែលជាក្នុងពុទ្ធសករាជ ៩០០-១២០០) សឹងបានប្រទះឃើញក្នុងគូហានៃវត្តព្រះពុទ្ធសាសនាជាច្រើន (ពាក្យថា គូហា ក្នុងទីនេះ គឺគុហាដែលគេចោះថ្មភ្នំជារូង ហើយសាងព្រះស្តូប ឬព្រះចេតិយ បញ្ចុះព្រះពុទ្ធរូបទុកក្នុងទីនោះ) ។

អ្នកសិក្សាបុរាណគតិគួរសង្កេតមើលព្រះពុទ្ធរូបពុម្ព រូបទី ២ កាល

ពិនិត្យទៅហើយ នឹងឃើញព្រះពុទ្ធរូបនោះអង្គុយសំយុងព្រះបាទបែបយ៉ាង បារាំង ឬបែបអង្គុយកៅអី មិនអង្គុយបត់ព្រះបាទដូចបែបប្រទេសបូព៌ា រូបខ្លាក់ផ្សេង ៗ នៅក្នុងគុហាស្រុកអជន្តា ស្រុកកាន់ហេរី ស្រុកការ្លី ស្រុក អេល្លោរះ នឹងនៅតាមគុហាដែលជាវត្តព្រះពុទ្ធសាសនាដទៃ ៗ ទៀតខ្លះទៅ ក៏សុទ្ធតែជាបែបអង្គុយសំយុងព្រះបាទទាំងអស់ រូបខ្លាក់ចាស់ ៗ ដែល ជីកទៅប្រទះឃើញនៅកំឡុងនគរបឋម និងព្រះពុទ្ធរូបប្រធានក្នុងវត្តយៃ ឬវត្តបឋមចេតិយ ក៏សុទ្ធតែជាបែបនេះដែរ ។

ម្យ៉ាងទៀតក្នុងគូហា ១ ដែលហៅថាគុហាឫសីខៅខ្ទូដ៏តាំងនៅខាង កើតទីក្រុមឿងនៃខេត្រាកជបូរីរបស់សៀម មានព្រះពុទ្ធរូបខ្លាក់ ១ អង្គនៅ ក្នុងគុហានោះ អង្គុយសំយុងព្រះបាទសម្តែងធម៌ដូចព្រះពុទ្ធរូបដែលបាន ពោលមកហើយ មានអក្សរបាលីខ្លី ៗ ជាអក្សរសម័យពុទ្ធសករាជ ៩៥០-១១៥០ ប្រាប់ទុកថា រូបខ្លាក់នេះជាស្នាដៃរបស់ឬសី អ្នកនៅក្នុងគុហា នោះសាងក្នុងសម័យនោះសឹងមាននាមថា សមាធិគុប្ត កាលយើងត្រួត-ត្រាមើលមកដល់ត្រង់នេះ ក៏មានមូលហេតុល្មមនឹងកំណត់ថា ព្រះពុទ្ធ រូបទី ២ និងព្រះប្រធានក្នុងវិហារវត្តព្រះបឋមចេតិយ មានសេចក្តីទាក់ ទងគ្នាយ៉ាងម្តេចម្យ៉ាង ទាំងអាចនឹងកំណត់អាយុសម័យនៃព្រះពុទ្ធ ដែល មានលក្ខណៈដូចគ្នាបានថា កើតឡើងក្នុងសម័យពុទ្ធសករាជ ៩៥០-១ ៥០ ម្យ៉ាងទៀតព្រោះព្រះពុទ្ធរូបអម្បាលនោះមានបាលីគាថា យេ ធម្មា ដោយ អក្សរក្នុងសម័យនោះ សឹងមានតួយ៉ាងនៅ ៗ រូបទី ៣ ខាងស្តាំ ។

ក្នុងសម័យនោះ មានសេចក្តីកត់ហេតុរបស់ចិនពោលទុកយ៉ាងច្បាស់លាស់ថា នៅជ្រោយមួយអន្ទើរវាងស្រុកស្រីក្សេត្រ (របស់ភូមា) និងស្រុកឥសាណបុរី (របស់ខ្មែរ) មានរាជអាណាចក្រឈ្មោះ ទ្វារវតី ឯពាក្យថា ទ្វារវតី មកប្រាកដជាឈ្មោះក្រុងស្រីអយុធ្យា ដែលព្រះចៅអ៊ូថោងសាងឡើងកាលពុទ្ធសករាជ ១៨៩៣ តែចូលចិត្តបាទថា ព្រះចៅអ៊ូថោងយកនាមចាស់មកប្រើហៅក្រុងដែលសាងថ្មី ។

ក្រុងទ្វារវតីចាស់នោះប្រហែលជាតាំងនៅស្រុកសុពណ្ណបុរី ឬស្រុកនគរបឋមឥឡូវនេះ កាលបើដូចនោះសោតគោងចូលចិត្តថា ព្រះពុម្ពសម័យព្រះបឋមចេតិយ ជាស្នាដៃរបស់អ្នកស្រុកទ្វារវតីសាងជាប្រាកដ ។

លំដាប់នេះនឹងពោលអំពីលក្ខណាការ នៃព្រះពុម្ពនោះជាដូចម្តេច ព្រះពុម្ពនោះជារូបព្រះពុទ្ធអង្គ ដួនកាលគង់លើផ្កាឈូក នៅទងផ្កាមាននាគ ២ ស្ពួយឡើង ដួនកាលជារូបព្រះពុទ្ធអង្គមានព្រះពុទ្ធរូបឯទៀតជាច្រើនអង្គចោមរោម លក្ខណាការនេះហៅថា មហាបាដិហារ្យ ដូចដែលពោលមកហើយខាងដើម ព្រះពុទ្ធរូបគ្រាមហាបាដិហារ្យនេះ ប្រាកដមានក្នុងប្រវត្តិព្រះពុទ្ធរូបគ្រប់ ៗ ប្រទេស ។

នឹងសម្តែងរឿងមហាបាដិហារ្យដោយសង្ខេប ដូចតទៅនេះ កាលព្រះបរមសាស្តាទ្រង់សម្តែងបាដិហារ្យបន្តិចបន្តួចក្នុងជាន់ដំបូង ហើយទ្រង់ហាមមិនឲ្យអ្នកឯណាទីមួយជាបព្វជិត ឬគ្រហស្ថឧបាសកឧបាសិកាយកតម្រាប់ធ្វើតាមក្នុងការដែលនឹងទរមានពួកតិរ្ថិយនិគ្រន្ថ ដោយសម្តែងឥទ្ធិ-

បាដិហារ្យឡើយ ព្រះអង្គទើបទ្រង់សម្តែងមហាបាដិហារ្យតាមពាក្យអាពធ-នារបស់ព្រះបាទបសេនទិកោសល ២ប្រការ ប្រការទី ១ ហៅថា យមកបាដិហារ្យគឺព្រះអង្គទ្រង់ដំណើរទៅមកលើអាកាសដោយឥរិយាបថផ្សេងៗ និងទ្រង់បណ្តាលឲ្យកើតជាអណ្តាតភ្លើង និងទឹកខ្យល់ ចេញអំពីសរីរព្រះ-អង្គ ទាំងភាគខាងលើនិងភាគខាងក្រោម ប្រការទី ២ គឺទ្រង់បណ្តាលឲ្យព្រះអង្គប្រាកដទៅសព្វទិសានុទិសក្នុងអាកាសវេហាស៍ និងគ្រប់ ៗ កន្លែងគ្រប់ ៗ អន្លើក្នុងទីជុំវិញ មានចំនួនច្រើនរាប់មិនគ្រប់ នៅវេលាកណ្តាលទីដែលព្រះរូបនិម្មិតរបស់ព្រះអង្គទៅប្រាកដ ព្រះអង្គទ្រង់សម្តែងធម៌ដោយព្រះអង្គឯង ក្នុងខណៈនោះវលាហកទេវបុត្រ បណ្តាលឲ្យកើតខ្យល់ព្យុះធំបោកបក់មកធ្វើឲ្យពួកតិរ្ថិយនិគ្រន្ថអប្បរាជ័យចាញ់វាលទៅអស់ ក្នុងគ្រាមានពួកតិរ្ថិយនិគ្រន្ថប្រែចិត្តបានត្រឡប់ចូលរាប់អានព្រះពុទ្ធសាសនា មានចំនួនច្រើនឥតបើរើងគណនាគ្រាប់ ៗ

នេះជាសេចក្តីសង្ខេបក្នុងរឿងមហាបាដិហារ្យ នៅមានរឿងដែលទាក់ទងគ្នាដោយព្រះពុទ្ធ មានយ៉ាងពិស្តារក្នុងក្បួនសំស្ក្រឹតឈ្មោះ (ទិវ្យា-វទាន) ទៀត ក្នុងក្បួននោះពោលថា ៗ

ក្នុងខណៈនេះ គឺខណៈដែលកំពុងធ្វើបាដិហារ្យ ព្រះដ៏មានបុណ្យទ្រង់រំពឹងដល់វារៈចិត្តនៃសត្វលោក មានធម្មតាមួយយ៉ាងគ្រាទុកថា កាលព្រះពុទ្ធអង្គ ១ ណាទ្រង់រំពឹងដល់វារចិត្តនៃសត្វលោកហើយ បណ្តាសត្វលោកទាំងពួង រហូតដល់ស្រមោចកណ្តៀរមែងដឹងដល់ព្រះពុទ្ធរំពឹងនោះរាល់ ១

គ្រា ហេតុដូចនោះព្រះឥន្ទ្រ ព្រះមហាព្រហ្មនិងទេវតាដទៃ ៗ ទើបគិតថា ព្រះពុទ្ធអង្គរំពឹងដល់ការចិត្តនៃសត្វលោកដោយបំណងអ្វីហ្ន៎ ក្នុងខណៈនោះ ទេវតាអម្បាលនោះ ក៏កើតសេចក្តីគិតឡើងក្នុងចិត្តថា ការដែលព្រះពុទ្ធអង្គទ្រង់រំពឹងដល់ការចិត្តនៃសត្វលោកនោះ ក៏គឺព្រះអង្គបំណងនឹងធ្វើនូវមហាបាដិហារនៅនគរសាវត្ថី ដើម្បីប្រយោជន៍ដល់សត្វទាំងឡាយ លុះគិតដូចនោះហើយ ព្រះឥន្ទ្រនិងព្រះមហាព្រហ្ម ព្រមដោយពពួកទេវតាជាបរិវារច្រើនសែនដែលដឹងការព្រះហឫទ័យព្រះដ៏មានបុណ្យ ទើបអន្តរធានបាត់មកអំពីវិមាននៃខ្លួន ៗ ទៅប្រាកដនៅទីចំពោះព្រះភក្ត្រព្រះបរមសា-ស្តា ព្រះមហាព្រហ្មនិងទេវតាទាំងឡាយដទៃ ៗ នាំគ្នាដើរប្រទក្សិណព្រះពុទ្ធអង្គ ៣ ជុំ ហើយចូលទៅថ្វាយបង្គំព្រះបាទយុគលដោយត្បូងវៀនកល់អង្គ ហើយក៏ចូលទៅអង្គុយវៀរកាយជាខាងស្តាំនៃព្រះសាស្តា ឯព្រះឥន្ទ្រនិងទេវតាដទៃ ៗ កាលបានសម្តែងសេចក្តីគោរពកប់អានស្រេច ហើយនាំគ្នាអង្គុយគាល់ជាខាងឆ្វេងព្រះបរមសាស្តា គ្រានោះស្តេចនាគ ២ ឈ្មោះនន្ទនិងឧបនន្ទ បាននិម្មិតជាផ្កាឈូក ១ មានត្របកផ្កាជាច្រើនពាន់ ធំប៉ុនកង់រថ ត្របកផ្កាបទុមអម្បាលនេះ សុទ្ធសឹងតែជាមាសទាំងអស់ ឯទងផ្កាជាពេជ្របុតទាំងអស់ ហើយទើបនាំផ្កាឈូកនេះ ចូលទៅថ្វាយព្រះបរមសាស្តា ៗ ស្តេចឡើងគង់ពែនព្រះភ្នែនលើត្របកផ្កានោះ ទ្រង់រំពឹងដល់ព្រះបារមីរបស់ព្រះអង្គហើយ ក៏ទ្រង់និម្មិតជាផ្កាឈូកបែបដូចគ្នានេះឡើង ផ្កា ១ ទៀតមានព្រះពុទ្ធអង្គគង់នៅខាងលើផ្កានោះដូចគ្នា ក៏

ប្រាកដជាព្រះពុទ្ធអង្គដែរជាសទាំងមុខទាំងខាងក្រោយ និងជុំ ៗ វិញ ព្រះអង្គជាច្រើនណាស់រាប់មិនអស់ ផ្សាយរហូតទៅដល់ជាន់អកនិដ្ឋ ជាពុទ្ធសភា ១ ដែលកើតអំពីព្រះពុទ្ធអង្គ ព្រះពុទ្ធនិម្មិតនោះ ៗ អង្គខ្លះបង្រ្គម អង្គខ្លះឈរ អង្គខ្លះអង្គុយ អង្គខ្លះផ្ទុំ អង្គខ្លះទ្រង់បណ្ដាលឲ្យកើតជាពន្លឺភ្លឺ អង្គខ្លះទ្រង់បណ្ដាលឲ្យកើតជាអណ្ដាតភ្លើង អង្គខ្លះទ្រង់បណ្ដាលឲ្យកើតជាផ្លេកបន្ទោរភ្លឺព្រាត ៗ ព្រះពុទ្ធនិម្មិតទាំងឡាយបានវិសជ្ជនាបញ្ហាផ្សេង ៗ ដែលកើតមានឡើងជាច្រើន ដោយព្រះគាថាទាំង ២ សឹងមានសេចក្ដីដូចតទៅនេះ ៗ

ចូរលះយកកសិរស័យ ហើយគប្បីបំពេញព្រហ្មចរិយក្នុងសាសនាព្រះពុទ្ធអង្គ ចូលទម្លាយសត្រូវពោលគឺមច្ចុរាជ បីដូចជាកុញ្ជរជាតិ (ដំរី) ទម្លាយខ្ទមដែលគេធ្វើដោយដើមអំពៅព្រៃដូចនោះ ៗ

បុគ្គលអ្នកប្រព្រឹត្តខ្លួនមិនចេញទៅក្រៅ ចាកពាក្យប្រដៅរបស់ព្រះពុទ្ធនិងរួចចាកសេចក្ដីកើត និងសង្សារវដ្ដ ហើយនឹងរំលត់ទុក្ខទាំងពួងបានបង់ដូចនេះ ៗ

ឯរូបពុម្ពនៅព្រះបឋមចេតិយ ថែបទី ២ ឃើញថាថ្មីជាងថែបទី ១ ដែលបានពោលមកហើយនោះ ទាំងគ្មានចារឹកអក្សរបុរាណជាគ្រឿងជួយសតិបញ្ញា នឹងបានកំណត់សម័យឲ្យត្រឹមត្រូវ ឬឲ្យជិតទៅបាន តែប្រាកដយ៉ាងច្បាស់លាស់ថា បើមិនជាស្នាដៃរបស់ខ្មែរពិតតែម្ដង ក៏គង់ជាស្នាដៃលាយខ្មែរ ព្រះពុទ្ធរូបអង្គុយ រូបទី ៤ នោះ មានលក្ខណៈប្រហែល

នឹងរូបចម្លាក់របស់ខ្មែរបុរាណ ហើយឯកំពូលស៊ុមដែលប្រាកដនៅរូបជាតួយ៉ាង ៣ រូប (គឺរូបទី ៦ រូបកណ្ដាល រូបទី ៧ ខាងស្ដាំនឹងខាងឆ្វេង) នោះជារូបប្រាសាទរបស់ខ្មែរស្មោះ ដូចដែលនៅនគរវត្ត មុនដែលប្រែកមកជាព្រះប្រាង្គណ៍សៀមគ្មានខុសត្រង់ណា ។

ព្រះពុទ្ធរូបពុម្ព ដែលគេបោះពុម្ពរួមគ្នា ច្រើនៗអង្គនេះ ចូលចិត្តថាគេធ្វើសំដៅគ្រាមហាបាដិហារ្យនោះឯង ឬធ្វើជំនួសរូបអតីតពុទ្ធអង្គ ១ សម្រាប់ ឬ ១ ឈុត លើសខ្វះខ្វះខ្វះ រូបអតីតពុទ្ធអង្គនេះ មានលក្ខណៈប្រហែលគ្នា នឹងរូបមហាបាដិហារ្យនោះណាស់ដែរ ។

បែបទី ២ ព្រះពុម្ពបែបទី ២ បានទីងព្រះពុម្ពផ្សេងៗ ដែលបានប្រទះឃើញក្នុងរូងគុហានៅទីជ្រោយមាលៃយូ មានចំនួនច្រើន ដូចដែលបានពោលមកហើយ ព្រះពុម្ពអម្បាលនេះគេធ្វើដោយដីឆៅ ឬដីស្អិតហើយហាលឲ្យឆ្អិនដោយកំដៅព្រះអាទិត្យបានមកពីវត្តហានទិងក្នុងខាងក្នុងដែនមឿងត្រាំងខ្លះ បានមកពីក្នុងខុមខាងមឿងជ័យាខ្លះ បានមកពីក្នុងអុកជុះ និងគុហាសវ័នមឿងព័ទលុងខ្លះ ក្រៅអំពីព្រះពុទ្ធរូបហើយនៅមានរូបព្រះពោធិសត្វ អវលោកិតេស្វរៈ ឬលោកេស្វរៈនៅជាមួយផង គាថា យេ ធម្មា ។ ដែលចារឹកមានតែជាភាសាសំស្រ្កឹតមួយយ៉ាង ភាសាបាលីគ្មានសោះឡើយ ១នេះធ្វើឲ្យមុខគួរជឿថា ពួកសប្បុរសជនអ្នកសាងព្រះពុម្ពបែបនេះ ជាអ្នកកាន់សាសនាលទ្ធិប៉ែកមហា-

យានដោយពិតព្រះពុទ្ធដ៏មាននៅជ្រោយមល្ហៃយូ ថែបខ្លះដូចរូបចម្លាក់នៅស្រុកផ្សេង ៗ រាងឥណ្ឌូនិងជ្វា រឿងនេះមិនចំឡែកប្លែកអស្ចារ្យអ្វីឡើយ ព្រោះអាណាចក្រប្រទេសស្រីវិជ័យ ដែលតាំងរាជធានីនៅស្រុកប៉ាលេមបាំង ក្នុងកោះសុមាត្រានោះ កាលពុទ្ធសករាជ ១១៥០-១៧៥០ បានរាតត្បាយអាណាខេត្តទៅដល់លើជ្រោយមល្ហៃយូ ខាងទិសលើរហូតដល់មឿងជ័យា រូបព្រះពោធិសត្វដ៏ល្អដែលក្រុមព្រះដំរុងរាជានុភាពបានប្រទះនៅមឿងជ័យានោះ ជាស្នាដៃវិចិត្ររបស់អាណាចក្រស្រីវិជ័យ តាំងព្រះពុទ្ធថែបទី ២ នេះ ក៏ប្រហែលជាស្នាដៃយ៉ាងល្អបំផុតរបស់អាណាចក្រនេះមានចំនួនច្រើនណាស់ដែរ ។

(មានតទៅទៀត)

អំពីលំនាំដើម

ហេតុនៃការដែលបានស្គាល់ប្រាសាទអង្គរ

លោក វិកទ័រគោលូបែវ

អគ្គលេខាធិការ នៅសាលាបារាំងសែសចុងបូព៌ាប្រទេស អធិប្បាយ

ក្រុមការ ជុំ-ម៉ៅ ធ្វើការនៅព្រះរាជបណ្ណាល័យ ប្រែជាភាសាខ្មែរ

(១)

ដែលបានឃើញអង្គរជាដំបូងនោះគឺក្នុងឆ្នាំ ១៦០០ អ្នកបួសម្នាក់នៅក្នុងក្រុមសាំងដូមីនិក ឈ្មោះគាប្រីយែល គីរូគា នៅស្រុក ស័នអន្តូនីអូ ក្នុងប្រទេសអាមេរិក ចារិកទុកក្នុងសៀវភៅមួយដែលបោះពុម្ពនៅស្រុកវ័ល្លាដូលីដ កាលក្នុង ១៦០៤ ថាមានទីក្រុង ១ ចម្លែកដែលពួកព្រានជាតិស្រុកអាយបានប្រទះឃើញ ក្នុងកណ្ដាលព្រៃខ្មែរក្នុងឆ្នាំ ១៥៧០ ជាទីក្រុង ដែលអស់ទាំងអ្នកស្រុកមិនដែលឃើញមិនដែលស្គាល់ នោះនៅលើដីទំនាប មាត់ទន្លេមកុងចម្ងាយ ១៧០ លៀ គឺ ៦៨០ គីឡូម៉ែត្រ ពីសមុទ្រ ទឹកឡើងនឹងជោរជាបដល់ទីនោះ ដូចជាក្រុងក្វាដ័លគីវីរ នៅស្រុក សេវិល ដែរ ក្រុងនោះសំណាក់ដៃដែលធ្វើសំខាន់ណាស់ ហើយមានតាំងកំផែងថ្មជុំវិញចំនួន ៤ លៀ (១៦ គីឡូម៉ែត្រ) កម្រាស់ ៤ ប្រាស គឺ ៦ ម៉ែត្រ ៤៨ សង្ទីម៉ែត្រ កំពស់ ៥ ប្រាស គឺ ៨ ម៉ែត្រ ១០ សង្ទីម៉ែត្រ មានចន្លោះជិតៗគ្នា ហើយរចនាជារូបដំរី ឆ្មាបារ ខ្លាធំ សីហ ឥន្ទ្រី និង ឆ្កែ ឃើញមានសិលាចារឹកជាច្រើនដែលមនុស្សមិនដែលដឹង

តាំងគេហស្ថានសុទ្ធតែថ្មដ៏ប្រសើរ ហើយចែកជាផ្លូវមានរបៀបរៀបរយល្អ ការងារនៃគេហស្ថានតាំងនេះសង្កេតមើលទៅត្រង់ទ្វារ ហាប់នឹងបន្ទប់ហាក់ដូចជាថ្មីដៃជាតិ រ៉ូម៉ង់ ឃើញមានម៉ាស៊ីនទឹកនឹងប្រឡាយទឹកជាច្រើនសម្រាប់ការសំអាត ហើយឆ្ងាយៗពីគ្នាបន្តិចទៅ ឃើញមានវត្តនឹងទីក្រុងតាំងឡាយទៀត សេចក្តីអធិប្បាយពីអង្គរនេះ មានសេចក្តីមួយជាភាសាស្រុកអឺរ៉ូប ដែលជាសេចក្តីចាស់ជាងគេនោះ មានដូចជាបំណោទដែលគេប្រទះឃើញក្នុងឆ្នាំ ៩០០ ហើយដែលពួកកេពង្សាវតារនិងក្បាច់អលង្ការណ៍ទំស្ទះស្វែងរក ក្នុងជាន់នោះនគរខ្មែរមានទីក្រុងដែលកប់បាត់ទៅក្នុងព្រៃឥតមានដំណឹង ហើយពង្សាវតារក៏សាបសូន្យទៅក្នុងព្រៃធំនោះទៅ មានសេចក្តីកត់សម្គាល់ពីអង្គរ១ទៀតក្នុងឆ្នាំ១៦៧៤ដែលមានប្រយោជន៍ដូចសេចក្តីមុនដែរ សេចក្តីនោះអ្នកបួសជាតិបារាំងម្នាក់ឈ្មោះសេវ្រើយ បាននិយាយថា មានប្រាសាទ ១ ដ៏វិចិត្រចម្ងាយពីកន្លែងដែលខ្ញុំនៅចំនួន ៨ ថ្ងៃ ប្រាសាទនោះឈ្មោះអង្គរ ជាប្រាសាទ ១ យ៉ាងឆើតដូចប្រាសាទស័ងព្យេរនៅក្រុងរ៉ូមដែរ សំអាងនេះឃើញប្រាកបជាប្រាកដនឹងសៀវភៅដែលនិយាយពីសសរទីងជញ្ជាំងអង្គរវត្ត ឯរឿងដែលចាស់ជាងគេនោះ បានធ្វើក្នុងឆ្នាំ ១៦០០ ។

សេចក្តីតាំងនេះ អធិប្បាយថាប្រាសាទនេះ នៅវេលាដែលគេបានឃើញហើយនឹងទៅជាកន្លែង ១ ដ៏ឧត្តម សម្រាប់អ្នកដំណើរ ។

គេមានដាំដើមពោធិ៍នៅទីនោះ គេបើកសេចក្ដីឯកចិត្តឲ្យខ្ញុំកំដរ គេឆ្លាក់ទីងផ្លូលផុលរូបតាំងឡាយ ក្នុងកាលនោះប្រហែលជាមានផ្លូសផុលខ្លះ តែមិនសូវប្រសប់ហើយឃើញមានស្នាមខ្លះដល់សព្វថ្ងៃនេះ ជាក្រោយតពីសង្ឃ្រាជសេរីយនេះមក មិនដែលមានជាតិបារាំងណាម្នាក់និយាយអំពីទីក្រុងនេះឡើយ ហើយក្នុងវេលានោះទីក្រុងនេះហាក់ដូចជាក្រោកឡើងបន្តិចពីដំណេក ក៏ប្រុះដេកសន្ធប់សន្ធិនទៅវិញ ឥតកម្រើក លុះដល់មកក្នុងកាលអ្នកដំណើរជាន់ក្រោយ ដែលចំរុកកនរកក្នុងឆ្នាំ ១៩០១ ទើបបានឃើញទីក្រុងនេះច្បាស់ឡើងវិញ ។

លោកហង់រីមូហុត មកដល់ក្នុងប្រទេសឥណ្ឌូស៊ីនក្នុងឆ្នាំ ១៨៥៨ លោកនេះជាអ្នកសង្វាតរុករកស្រុកប្រទេស ដែលពួកសាកិមិង្គនិងពួកស៊ុសៀ បានចេញពីប្រទេសអឺរ៉ុបមកស្វែងសួរក្នុងអាកាសព្រៃក្ដៅជាទីពាញ់ ដើម្បីចំរិះរកឥតនឿយណាយ លោកហង់រីមូហុតគ្មានធ្វើទុកក្នុងចិត្តថានឹងបានឃើញទីក្រុង ១ ដែលមិនស្គាល់ឡើយ ប៉ុន្តែលុះមកដល់ត្រើយហើយបានប្រទះឃើញប្រាសាទបាក់បែកក្នុងស្រុកខ្មែរ នោះក៏មិនរញ្ញួកនឹងចំប្រឹងពិនិត្យសង្កេតឲ្យច្បាស់ឡើយ គឺនៅវេលាដែលបានចូលទៅក្នុងខេត្តបាត់ដំបងដែលនៅជាខេត្តសៀមនៅឡើយ ទើបដឹងថានៅខាងកើតទន្លេសាប មានទីក្រុងបុរាណដែលបាក់បែកអន្តរាយ អ្នកបួសជាតិបារាំងម្នាក់ឈ្មោះ ស៊ីលវេស្ត្រ ក៏បានជូនដំណើរទៅនៅថ្ងៃ ២២ យ៉ាំង

រីយេ ១៨៦១ ពេលព្រះអាទិត្យរះ លោកមូហុតបានប្រទះឃើញកំពូលប្រាសាទអង្គរវត្ត ក្នុងប្រជុំមែកឈើដែលមានវល្លិ៍ខ្ទួតខ្ទួចទៅវិញទៅមក ។

សេចក្តីដែលអ្នកដំណើរនេះបានតែង អំពីដែលបានមកមើលប្រាសាទនោះ គេមិនអាចនឹងមើលហើយឥតសេចក្តីសោមនស្សព្រឺព្រួចឡើយ លោកនៅតែម្នាក់ឯងក្នុងព្រៃស្ងាត់ ហើយតាំងពិចារណាគិតរកសេចក្តីខ្វល់ខ្វាយអស្ចារ្យ ដែលកន្លងមកហើយ ប៉ុន្តែឯប្រាសាទបាក់បែកនីមួយ ៗ នោះ មានជាការដែលពិបាកនឹងគិត មានឮសព្ទដំរីស្រែកពីចម្ងាយ ហើយជួនកាលមានសត្វខ្លា គ្រោកស្ទុះរត់ក្នុងព្រៃស្ងាត ទៅខាងក្រោយក៏តែងឃើញដើមពោធិ៍ដែលដុះមកជាច្រើនឆ្នាំហើយ មានស្ទូកាន់នៅជាប្រក្រតី ជួនកាលមានសត្វពស់ស្ទុះរត់មើលមិនទាន់ ឯមនុស្សជាតិស្រុកអាយ ដែលអ្នកដំណើរនេះបានសួរពត៌មានអំពីប្រាសាទទាំងនេះទៅ ឆ្លើយប្រាប់មកវិញមិនច្បាស់លាស់សោះ ថាអង្គរនេះគឺស្តេចទេវតាបានសាង ដោយមានយក្សជួយផង ហើយថាពួកស្ត្រីទេពអប្សរ បានយោងដុំថ្មឃ្លាយក្រៀមដែលជាងមានថ្វីដៃធ្វើឡើងទៅលើ ហើយព្រមទាំងបង្ហាញដល់អ្នកដំណើរនេះ សំណាមម្រាមដៃដែលជាប់នៅថ្មថាជាម្រាមដៃទេវតា រួចពីនោះក៏បាននិយាយពីស្តេច ១ អង្គដែលកើតឃ្លង់ ដែលមានរូប ១ នៅតែម្នាក់ឯងលើដីវាល មានស្នៅលួតលុបក្នុងស្បាត ។

លោកហង់រីមូហុតមរណភាពទៅ នៅវេលាក្រោយ ដែលបានរកឃើញអង្គរវត្តរួច ឯសេចក្ដីកត់សម្គាល់នឹងគំនូរដែលលោកបានគូរ បោះជាក់ក្នុងកាសែត "ជុំវិញទ្វីប" ខេះក៏ញុំាងសាធារណជនឲ្យដឹងគ្រប់គ្នាការដែលលោករកឃើញទាំងប៉ុន្មានអំពីប្រាសាទខ្មែរនោះ មិនត្រូវឲ្យសាបសូន្យទៅវិញឡើយ ។

ឆ្នាំដែលរកឃើញប្រាសាទបុរាណទាំងនេះ ត្រូវនឹងឆ្នាំដែលក្រុងបារាំងសែសមកយកស្រុកកូសាំងស៊ីន នឹងឆ្នាំដែលមានសេចក្ដីប្រស្រ័យទៅវិញទៅមក របស់រាជការបារាំងសែសនិងរាជការសៀម ដែលជាទីនាំឲ្យបង្កើតរាជការទំនុកបម្រុងក្រុងកម្ពុជា ។

ក្នុងឆ្នាំ ១៨៦៤ មន្ត្រីសៀមម្នាក់ដែលតំណាងរាជការស្រុកសៀមមកក្រុងភ្នំពេញនោះ គេបានហៅឲ្យចូលទៅវិញ ដូចនេះឃើញថាអំណាចផែនដីសៀមដែលផ្សាយលើក្រុងកម្ពុជា ជាច្រើនរយឆ្នាំនោះ ផុតត្រឹមឆ្នាំនោះហើយ ។

ភ្នាក់ងារបារាំងសែសដែលទទួលបង្គាប់ មកតាំងអាណាព្យាបាលថ្មីនោះ គឺមេកប៉ាល់ម្នាក់ឈ្មោះអែរ៉ែណេសមារក៍ឌូដារត៍ដឺឡាគ្រេ លោកគំនិតដ៏ដឹឡាគ្រេនេះ ជាទាហានមានតម្លៃ ហើយប៉ិនប្រសប់ បានធ្វើការដ៏ប្រសើរនេះឲ្យសម្រេចបាន មិនជាយូរប៉ុន្មានលោកបានពាក់របៀបក្នុងស្រុកខ្មែរ ឲ្យបានសេចក្ដីសុខសេចក្ដីចម្រើន ដែលតាំងពីដើមរៀងមក

ទល់ត្រឹមនោះ មិនដែលឃើញមានសោះក្នុងក្រុងកម្ពុជា ដែលជានគរ តែងតែនៅក្នុងអំណាចមនគរឯទៀត ។

ទៅវេលាដែលមកតាំងនៅក្រុងភ្នំពេញ លោកកុំម៉ង់ដង្ដឌូដារត៍ដឺឡាគ្រេពិចារណារិះរករៀបចំ សេចក្ដីស៊ីវិល័យរបស់ជាតិខ្មែរ និងរុករកប្រាសាទបុរាណ ដែលលោកមូហុតបានរកឃើញក្នុងតំបន់ទន្លេសាបនៅវេលាដែលបើកកប៉ាល់ល្បាតក្នុងសមុទ្រមេឌីទែរេណេ នោះលោកល័យីគីណង្ដជំទង់នេះបានធ្វៀតទៅ.មើលប្រាសាទអាក្រប៉ូល នៅស្រុកក្រិកផង ហើយនៅវេលាដែលបានមកឃើញប្រាសាទអង្គរនោះ ក៏ហាក់ដូចជាប្រាសាទរបស់ស្រុកក្រិកកើតឡើងនៅមុខជាថ្មីទៀត ។

បានពិនិត្យមើលប្រាសាទទាំងនេះជាច្រើនដង ហើយអធិប្បាយអំពីក្បាច់ចម្លាក់ អំពីគំនូរ អំពីផែនទី និងភាពសណ្ឋានទីក្រុង ។ លោកឌូដារត៍ដឺឡាគ្រេ បានជួបនឹងអ្នកដំណើរជាតិអាំងក្លេសម្នាក់ឈ្មោះ ស-ជុំសុន ដែលទើបតែនឹងថតយកបែបអង្គរវត្តហើយៗ ក៏បានស្គាល់គ្នានៅទីនោះ ឯរូបថតជាប់នឹងកញ្ចក់ដែលលោក ស-ជុំសុន ថតបាននោះ ញុំាងឲ្យលោកឌូដារត៍ដឺឡាគ្រេ គិតឃើញដល់សេចក្ដីត្រូវការលើវត្ថុនោះ ដែលក្នុងកាលនោះមិនទាន់មានជាញឹកញាយនៅឡើយ ហើយលុះដំណើរជាន់ក្រោយបាននាំអ្នកថតរូបទៅជាមួយផង ។

ក្នុងពេលជាមួយនោះ បានចាក់ការរើកទូទៅទាំងអស់ បានប្រែពង្សាវតារស្រុកខ្មែរជាភាសាបារាំងសែស រឿងក៏រដែលចារឹកជាអក្សរ

តាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យបានយល់ដល់ទគរខ្មែរពីដើមនោះ បាន ប្រមូលផ្តុំគ្នាហើយពិនិត្យទ្រួតត្រាដោយម៉ត់ចត់ បានយកលោកសង្ឃដែល ស្ទាត់ខាងអក្ខរវិធី មកជួយពិគ្រោះ ឯរឿងរ៉ាវតាំងប៉ុន្មានរនោះ ក៏កាន់តែ ចូលជាពង្សាវតារបន្តិចម្តង ៗ ហើយប្រាសាទអង្គរក៏អស់ទៅជាសេចក្តី អស្ចារ្យទៅវិញតាំងពីនោះមក ឯឈ្មោះស្តេច ដែលគ្រងរាជ្យក្នុងក្រុងនេះ បានស្គាល់ឡើងវិញ ។

ក្នុងឆ្នាំ ១៨៦៦ លោកកុំម៉ង់ដង់ដឺឡាគ្រេ បានទៅកាន់អង្គរទៀត ជាមួយនឹងក្រុមជំនុំរិជ្ជាលោក១ក្រុម ដែលទើបនឹងតាំងបង្កើត ដើម្បីពិនិត្យ ទន្លេមេកុង ហើយដែលលោកកុំម៉ង់ដង់ដឺឡាគ្រេនេះជាអធិបតី ដំណើរ ទៅមើលនេះគឺជាដំណើរជាន់ក្រោយ បំផុតរបស់លោក ក្នុងថ្ងៃ ១ នោះជា ថ្ងៃក្តៅ ពួកក្រុមជំនុំតាំងនេះជិះលើខ្នងដំរីដើរលេងជុំវិញអង្គរវត្ត ថ្ងៃក្រោយ គទៅទៀតទៅលេងឯប្រាសាទបាយ័ន វិមានអាកាសនិងប្រាសាទខ្លះឯ ទៀតផ្សេង ៗ នៅថ្ងៃ ១ សូរយេតក្រុំជំនុំតាំងនេះបានវិលត្រឡប់ពីប្រាសាទ បុរាណ មកប្រជុំជួបគ្នាវិញនៅកប៉ាល់សាលុបលេខ ២៧ ចតនៅមាត់ស្ទឹង សៀមរាប នៅវេលាក្រោយដែលបានឈប់នៅផ្ទះចៅហ្វាយស្រុកជាតិ ស្រុកអាយបន្តិច ។

ក្នុងពួកលោកឧដារតដឺឡាគ្រេតាំងប៉ុន្មានរនោះ មានអ្នកហ៊ីស្សេរ កប៉ាល់ជំទង ២ នាក់ ដែលអង្គរល្បីឡើងដោយមនុស្សតាំងពីរនាក់នេះ គឺលោកហ្វ្រង់ស៊ីគាទេញ និង លោកល្វីដឺឡាពារត៍ ។

ជនទាំងអស់គ្នាក៏បានស្គាល់ការ ដែលលោកហ្វ្រង់ស៊ីការនីញេបានធ្វើ អំពីដែលបានពិនិត្យទន្លេមេគុងប៉ែកខាងលើ អំពីត្រឡប់មកក្នុងប្រទេសឥណ្ឌូស៊ីន កាលក្រោយច្បាំងពីឆ្នាំ ១៨៧០-៧១ អំពីតយុទ្ធនឹងពួកចោរចិន (ប៉ាវីយ៉ុងណ្វា ឬពួកទង់ជ័យខ្មៅ) ដែលនាំឲ្យលោកមរណភាពក្នុងស្រុកហាណូយហើយបណ្ដាលឲ្យបានវាយយកស្រុកតុងកឹង ប៉ុន្តែប្រហែលជាមានមនុស្សជាច្រើនមិនដឹងគំនិតរបស់លោកនេះ ដែលលោកបានផ្ដេជ្ញាចិត្តក្នុងជាតិនេះថា នឹងត្រឡប់ទៅមើលអង្គរជាថ្មីទៀតឡើយ ហើយនឹងបានធ្វើជាអ្នករក្សាទូវប្រាសាទបុរាណ ដរាបលុះដល់កំណត់ឈប់លែងធ្វើរាជការ ក្នុងសេចក្ដីកត់ត្រារបស់លោកហ្វ្រង់ស៊ីការនីញេនោះមានច្រើនភាគដែលនិយាយអំពីក្បាច់អលង្ការខ្មែរ ដែលជាសេចក្ដីពីរោះ សេចក្ដីសរសើរពីស្នាដៃរបស់ជាងដែលធ្វើនោះ មានជាច្រើនទំព័រ លោកបាននិយាយសរសើរថាដូចនេះ “ សប្បាយអ៊ីម្ល៉េះ ដែលបានឃើញខាងនេះថ្ម ខាងនោះរូប ហើយបន្តិចទៅទៀតប្រាសាទ” លោកពិបារណារកបែបសាងប្រាសាទដែលបាក់បែកទៅ ដើម្បីដាក់ក្នុងផែនទីបញ្ចូលទៅជាមួយនឹងប្រាសាទបុរាណ ដែលរកឃើញហើយ ហើយលោកនិយាយតទៅទៀតថា “ យូរទៅទៀតគង់តែនឹងឃើញមានក្នុងស្រុកខ្មែរប្រាសាទផ្សេង ៗ ជាច្រើនដែលមិនទាន់បានស្គាល់ក្នុងព្រៃធំ ៗ ដែលសុទ្ធតែជាកន្លែងមនុស្សនៅកាលពីដើមទាំងអស់ ” ។

ការដែលលោកហ្វ្រង់ស៊ីការនីញេបានបំណងទុកនោះ មិនបានសម្រេច តែដល់ក្រោយមកលោកហ្វីដឡាពរត៍ជាមិត្រធ្វើឲ្យបានសម្រេចខ្លះដែរ ជាក្រោយដែលលោកកំម៉ង់ដង្ដដឹឡាគ្រេ មរណភាពទៅក្នុងឆ្នាំ ១៨៦៧ នោះគេបានគិតថាត្រូវចាប់ធ្វើការ ដែលមន្ត្រីនេះបានផ្ដើមធ្វើតទៅទៀតប្អឺ គ្មានអ្នកសង្ឃឹមថានឹងមានចាត់មនុស្សជំនួសមកធ្វើការនោះសោះឡើយ ដោយការនោះជាការធំណាស់ ប៉ុន្តែបើនឹងឲ្យមានជាការរិះរកក្បាច់អលង្ការដែលមានល្បីក្នុងស្រុកខ្មែរជាថ្មីវិញបាន ។

កាលក្នុងរដូវប្រាំង គឺរដូវក្ដៅក្នុងឆ្នាំ ១៨៧១ លោកអាមីរ៉ាល់-ប៉ូធុអូ ជាសេនាបតីក្រសួងជើងទឹកជាមួយនឹងលោក ស៊ុលស៊ីម៉ុង បានចាត់មីស្យុង១ក្រុមមកពិនិត្យប្រាសាទបុរាណខ្មែរនៅលើដែនស្រុកខ្មែរនិងដែនស្រុកសៀម បានចាត់លោកដឺឡាពរត៍ឲ្យត្រួតត្រាពួកមីស្យុងទាំងនោះ ២ ឆ្នាំតពីនោះកប៉ាល់ ១ ឈ្មោះ ឡាសឺវីលីង បានចេញពីព្រែន-ត មកជាមួយនឹងកប៉ាល់សាលុប ១ ក្នុងកប៉ាល់នោះមានពួកមីស្យុងនេះជិះ តម្រង់ទៅឯទន្លេសាប ពួកមីស្យុងទាំងនេះមានសុទ្ធតែពួកអ្នកប្រាជ្ញនិងពួកឥន្ទនាដែលសម្រាំងរើសយក ហើយមានពួកទាហានជើងទឹកជួយអមថែមទៀត ។

រឿងការអំពីដំណើរនេះ លោក ដឺឡាពរត៍ បានអធិប្បាយក្នុងសៀវភៅ១ ដែលបានគូរជារូបគំនូរដោយដៃឯង ឯចំណែកខាងអលង្ការផ្សេងៗ

ដែលយកពីស្រុកខ្មែរទៅនោះ បានយកទៅតាំងប្រឡងនឹងរបស់ឯទៀត ដែលមានក្នុងលោកទាំងមូល កាលពីឆ្នាំ ១៨៧៨ ហើយដែលបានទីដ៏ឧត្តម នៅកណ្ដាលក្បាច់អលង្ការណ៍ អេស៊ីប និងអលង្ការណ៍ចិន គ្រឿងអលង្ការណ៍នោះហើយ ដែលបានជាគ្រាប់ពូជនៃសារមន្ទីរខ្មែរនៅស្រុកត្រូកាដេរ៉ូសព្វថ្ងៃនេះ វេលាដែលមោទសៀរដឺឡាពរត៍ ត្រឡប់មកវិញ នោះអង្គរក៏តាំងមានជ័យដ៏ប្រសើរឡើង អស់ទាំងពុម្ពដែលធ្វើតំណាងប្រាសាទនោះក៏បានដំណឹងធ្វើឲ្យភ្ញាក់ផ្អើលដល់អ្នកស្រុកបារិសជាច្រើន អំពីបែបក្បាច់អលង្ការណ៍ខ្មែរ ដែលគេពិនិត្យតាមក្រោយលំអានគោលដើម នៃការដែលគេឆ្ងល់កល់គ្នាអំពីជាងឆ្លាក់ដែលមើលមិនយល់ ហើយដែលគេទើបតែនឹងបានដំណឹងថាមាន(១) ឯគំនូររបស់លោក ដឺឡាពរត៍ បានធ្វើផ្សាយទូទៅអំពីដំណើរដែលលោកបានជិះកប៉ាល់ឡូកសឺវីលីនមក គ្មានអ្នកឯណា១ បេះអធិប្បាយដូចលោក អំពីពងគៅច្រូងព្រាយយ៉ាងល្អ ឯគំនូរដែលលោកគូរនោះ មានឃើញព្រៃស្បាត មានដើមត្នោតនិងល្វៃដើមពោធិ៍ធំៗ នាំឲ្យនឹកឃើញដល់ថ្វីដៃរបស់ជាងលេខ ១ នៅស្រុកអ៊ីតាលីឈ្មោះពីកំណែស ។

លោកហ្សារ៉ូ ជាពួកមីស្យុង ដឺឡាពរត៍ បានរកឃើញអង្គរទី២ទៀត

---

(១) ភស្តុតាងដើមទុកនៅសារមន្ទីររបស់ខ្មែរនៅត្រូកាដេរ៉ូ នោះក្រុមជាងដែលតាំងរបស់នៅស្រុកម៉ារសីបានចេញប្រាក់សាងជាប្រាសាទ ១ តាមផែនទីអង្គរវត្ត គេបានដឹងអំពីថ្វីដៃក្រុមសាងទាំងនេះ ចម្លាក់អលង្ការណ៍ខ្មែរដ៏ប្រសើរ មួយទៀតនោះបានមកពីលោក អេមូនីញេ ដែលតាំងនៅសារមន្ទីរគីមេ ។

ទៅខាងជើងទន្លេសាប ចម្ងាយ ១៧៦០ ម៉ែត្រពីទីនេះទៅបៀតក្នុងព្រៃក។

ប្រាសាទបុរាណខ្មែរដែលគេស្គាល់ឈ្មោះ ជា "បន្ទាយឆ្មារ" នោះ មានកំផែងពីថ្មក្រហមនិងថ្មប្រផេះ កំពូលបាក់បែកដាច់ខ្ទេចខ្ទីនៅកណ្ដាលព្រៃស្ងាត់ដែលកើតព្រៃបំផ្លាញ ជាញឹកញយ ប្រាសាទនេះដូចជាអគ្គរធំដែរ មានរូបទេវតានិងនាគធំៗ ចាំផ្លូវ រូបមនុស្សមានមុខញញឹម ឯសសរទាំងឡាយនោះតជាប់គ្នាពី ១ ទៅ ១ ហើយ ឯជញ្ជាំងមានឆ្លាក់ជារឿងរ៉ាវបុរាណប៉ុន្តែឯអគ្គរ នៅវេលា ដែលគេបានរកឃើញក្នុងឆ្នាំ ១៦០០ នោះ គេបានស្គាល់ថា ជាកន្លែងដែលគេបានតម្កល់សាសនានៅវេលាក្រោយមកទៀត ឯបន្ទាយឆ្មារនោះគេក្ដេចបោលនៅក្នុងព្រៃ លុះដល់បារាំងសែសមក ទើបបានរកឃើញឡើងវិញ ហើយសព្វថ្ងៃនេះ ក៏នៅតែស្ងប់ស្ងាត់ទៀតព្រោះតែសម្លេងសត្វក្ងោកនិងស្វានិងស័ព្ទស្លឹកឈើជ្រុះ ។

ឯពង្សាវតារស្ដេចស្រុកខ្មែរដែលលោកដឺឡាគ្រេ បានប្រែនោះមានតែរឿងរ៉ាវស្ដេចក្នុង ៦០០ ឆ្នាំមុននេះ ក្នុងមហាសករាជដែលត្រូវនឹងឆ្នាំសាងប្រាសាទអគ្គរនិងប្រាសាទផ្សេងៗ នោះ ពង្សាវតារនេះគ្មាននិយាយបន្តិចសោះមានតែប្រាសាទបុរាណដែលមានចារឹកអក្សរ ដែលសាងដោយកន្លែងផ្សេង ៗ ក្នុងគនរខ្មែរ ទើបមានអធិប្បាយអំពីពង្សាវតារស្រុកខ្មែរច្បាស់លាស់ល្អ ឯប្រាសាទទាំងឡាយនេះ ដូនកាលជាផែនថ្មលើកឡើងនៅជាប់ពីគេមានចារឹកអក្សរ ដូនកាលជាអក្សរឆ្លាក់នៅលើខ្លោងទ្វារឬជញ្ជាំងធ្វើឲ្យអ្នក ដែលពិនិត្យរិះពិចារណាដោយមាំមួន ចារឹកខ្មែរទាំង

ឡាយនោះ បានបញ្ចូលក្នុងពួកចារឹកទាំងប៉ុន្មាន ដែលមានប្រទេសអាស៊ី អក្សរទាំងឡាយបានធ្លាក់ត្រឹមត្រូវឥតល្អៀង ដែលគេមិនធ្លាប់ប្រទះឃើញ ចារឹកឯណាក្នុងឆ្នាំជាមួយនោះ បំពោះក្នុងនិងប្រជុំអក្សរទាំងនេះ គេមិន អាចនឹងមិនឈ្វេងយល់បានអំពីឥទ្ធិឫទ្ធិ និងជ័យជម្នះរបស់ស្តេចនៅអង្គរពី ដើមឡើយ មានចារឹកជាច្រើនក្នុងពួកនេះ ធ្លាក់ជាពាក្យសំស្ក្រឹត គេ មើលចារឹកទាំងនោះទៅ មិនឃើញមានទាស់អ្វីសោះ ហើយឯចារឹក ដែលធ្លាក់ជាភាសាខ្មែរ ក៏មានប្រការដូចគ្នា ដើម្បីនឹងមើលអក្សរទាំង នេះឲ្យច្បាស់សេចក្តី នោះគាត់ប្រជុំពួកអ្នកប្រាជ្ញធំៗ ដែលស្ទាត់ខាង វិជ្ជាស្រុកឥណ្ឌា គឺលោកបែរគែញ ១ លោកបារថ៍ ១ និងលោកអាចារ្យ គែរន៍ នៅសាលាប្រជុំជាន់ខ្ពស់ នៅស្រុកឡីដឺ ១ ។

អ្នកដែលពិនិត្យមើលអក្សរខ្មែរនោះ ត្រូវរាប់បញ្ចូលលោកលីយើ តីណាន់អេមូនីញេ ដែលជាអ្នកចាប់ធ្វើការដោយមុនប្រសប់អំពីលោក កុំម៉ង្តង់ឌុដារត៍ដឺឡាគ្រេមក តាំងពីឆ្នាំ ១៨៧៤ មន្ត្រីនេះ បានបង្កើត ជាដំបូងសៀវភៅសព្ទវចនា បារាំង-ខ្មែរ អ្នកប្រាជ្ញនេះ ចេះតែខំសង្កាត ធ្វើឲ្យយើងចេះដឹងជាច្រើន អំពីនគរខ្មែរកាលពីដើម លោកបានរក ឃើញចារឹកជាច្រើននៅក្នុងព្រៃ ឯចារឹកទាំងនេះនាំឲ្យបានជាប្រដាប់ដំបូង ដែលជាប្រយោជន៍ក្នុងការរិះរកពង្សាវតារស្រុកខ្មែរ ក្នុងកំពីរផ្តាច់ឆ្នាំ ក្នុងឆ្នាំ ១៨៨២ លោកសេណាសឺណាន់ បានអធិប្បាយថាដោយអំណាច ការងាររបស់លោកអេម៉ូនីញេ ទើបការទាំងឡាយក្នុងស្រុកខ្មែរ ដែល

កន្លងមកនោះក្តីច្បាស់ឡើង ហើយឯចារឹកសំស្ក្រឹតក៏បានលេចឡើងទៀត អ្នកប្រាជ្ញនេះបានបន្ថែមសេចក្តីថាដូចនេះ មានតែព្រះទើបបានជ្រាបថា សម្បត្តិអ្វីខ្លះដែលភាសាសំស្ក្រឹត ១ ភាគនេះ កប់ទុកឲ្យយើង ។

ពង្សាវតារដែលលោកអេមូនីញេ បានរៀបរៀងអំពីស្រុកខ្មែរ នោះបានបោះពុម្ពសៀវភៅ ៣ ក្បាល សៀវភៅទាំងនេះធ្វើឲ្យអង្គររស់ឡើងជាថ្មី ដោយសេចក្តីអធិប្បាយផ្សេង ៗ និងក្បាច់ចម្លាក់ដែលនៅលើផ្ទាំង ព្រមទាំងរឿងរ៉ាវ ទំនៀមទម្លាប់ស្រុក ឯពង្សាវតារនេះ មានលោកមូរ៉ា១, លោកហ្វូរនីរ៉ូ១, លោក ប៉ាវី១, លោកម៉ាស្ប៉េរ៉ូ១, លោកគ្រោលីយេ១, បានបំពេញបញ្ចប់ជាក្រោយទៀត ម្យ៉ាងវិញទៀតលោក ល្វី ហ្វីណូត៍ និងលោកសឺដេស បានខំរកតទៅតាមការ ដែលលោក បារថ៍ និងលោកបែរគែញ បានរិះរកអំពីអក្សរវិធី ហើយសព្វថ្ងៃនេះ យើងបានដឹងច្បាស់អំពីសេចក្តីស៊ីវិល័យនៃក្រុងកម្ពុជាកាលជាន់ដើម ហើយដែលយើងអាចនឹងបង្កើតជារឿង ជុំវិញប្រាសាទបុរាណបាន ឥឡូវនេះ យើងបានស្គាល់សម្បត្តិស្តេច ដែលគ្រងរាជ្យក្នុងអង្គរស្ទើរតែទាំងអស់ ដោយអំណាចចារឹកទាំងឡាយ ដែលបានរកឃើញ ចារឹកទាំងនោះធ្វើឲ្យយើងដឹងថា នគរដែលមានឫទ្ធិនោះ ចាប់តាំងពីឆ្នាំ៩០០ ទៅដល់ឆ្នាំ ១២០០ ហើយឯព្រំប្រទល់នគរនោះ គឺជាច្រើនជាងព្រំប្រទល់សព្វថ្ងៃនេះ ក្សត្រិយ៍ទាំងប៉ុន្មានដែលគ្រងរាជ្យក្នុងអង្គរនោះបើមិនមែនជាជាតិក្នុងស្រុក ក៏សុទ្ធតែ

កាន់ទំនៀមទម្លាប់តាមក្លឹងទាំងអស់(១) មានពួកព្រាហ្មណ៍ជាច្រើនសម្រាប់ទូន្មានស្តេច ឯភាសាដែលកប់អានជាងគេក្នុងព្រះបរមរាជវាំងនោះ គឺភាសាសំស្ក្រឹត ឯរបៀបពិធីបុណ្យនិងរបៀបធ្វើបុណ្យនោះមានលំអានដូចស្រុកក្លឹងទាំងអស់ តាំងពីរបៀបបន្ទាប់បន្សំឡើងទៅ គឺក្បួនហែគ្រឿងប្រដាប់តន្ត្រីគ្រឿងសាស្ត្រាវុធនិងគ្រឿងអលង្ការសម្រាប់ក្សត្រ ឯរបាំនោះលេងរឿងរាមាយណ៍ ក្សត្រនិងមន្ត្រីធំៗ ក្នុងព្រះបរមរាជវាំង នៅវេលាដែលដង្ហែចេញនោះ មានបាំងក្លស់និងតូរ្យតន្ត្រីរបាំហែតាមក្រោយ ដួនកាលសែងនឹងរមាស ដួលកាលជិះលើខ្នងដំរីមានក្រោលកម្រាល ឯស្តេចនិងមន្ត្រីទាំងនេះ មានកិរិយាដូចជាមនុស្សក្លាហាន ដែលមានក្នុងរឿងមហាភារត គឺចូលចិត្តនឹងល្បែងនឹងសេះនឹងចម្បាំងជាតិខ្មែរ មានបែបដូចជាជាតិឥណ្ឌូដែរ គឺចែកចេញជា ៤ ពួក ពិតមែនតែសំអាងក្នុងចារឹកទាំងឡាយមិនពិតប្រាកដ តែដែលជាប្រាកដនោះ គឺឃើញមានពួកបុរោ-ហិត ពួកព្រាហ្មណ៍អភិសេកស្តេចតាមទំនៀមទម្លាប់ឥណ្ឌូ អំពីស្រោចទឹកពួករាជគ្រូអាចារ្យដែលបង្ហាត់បង្រៀនស្តេចនោះ បានបង្រៀនវិជ្ជាផ្សេងៗ គឺវិធីគិតគូរលេខនិងក្បួនហោរា ក្បួនវេយ្យាករណ៍សំស្ក្រឹតនិង

(១) ដើមកំណើតជាតិខ្មែរនោះមិនទាន់ស្គាល់នៅឡើយ អាចារ្យកែរន៍ស្មានថាប្រហែលជាពួកដែលបែកមកពីស្រុកខាងលិច ប៉ុន្តែមិនឃើញមានពង្សាវតារអ្វីធ្វើឲ្យឃើញជាក់ប្រាកដសោះ ដរាបដល់មកសព្វថ្ងៃនេះ មើលសៀវភៅវេយ្យាករណ៍ដែលលោក ស័រ-ម៉ាស្បេរ៉ូ តែងពីឆ្នាំ ១៩១៥ ក្នុងភាគទី ១ ។

លក្ខណបញ្ញត្តិផ្សេងៗ ពួកព្រាហ្មណ៍ និងគ្រូទាំងនេះ ចាត់ការកសាងទេវស្ថានផ្សេងៗ និងរៀបចំត្រួតត្រាវេហាពលទាំងឡាយ ម្យ៉ាងវិញទៀតបានបង្រៀននូវធម៌ស្ងាត់កំបាំងដល់ស្តេច ដែលលោកអេមូនីញេឃើញថាជាការធ្វើពលីការបូជាផ្សេងៗ ។

ចារឹក ១ ដែលរកឃើញនៅប្រែបអង្គរវត្ត ហើយដែលលោកបែរកែញបានប្រែនោះ ពង្សាវតារពូជព្រាហ្មណ៍ដែលមកនៅស្រុកខ្មែរ ដោយសេចក្តីមេត្តាករុណា ហើយដែលជីតាជីដូនកើតនៅស្រុកឥណ្ឌ វេលាដែលមើលចារឹកនោះទៅ ហាក់ដូចជាខ្លួនយើងទៅនៅក្នុងលោក ១ផ្សេង ដែលគេសិក្សាតែមន្តអាគម ហើយដែលអ្នករៀនសូត្រកាន់នៅផ្លូវបង្អៀត គឺធ្វើទុក្ករកិរិយា ទំសិក្សានូវក្បួនវេទផ្សេងៗ សេចក្តីនោះធ្វើឲ្យឃើញថាជាន់នោះ ព្រះឥសូរឫស៊ីរុងរឿងក្តីបីដូចព្រះអាទិត្យទាំង ១០០ ។

នៅប្រែបសាសនាឥណ្ឌ មានពុទ្ធសាសនាដែលកាន់តាមលទ្ធិមហាយាន ផ្សាយជាច្រើនទូទៅក្នុងស្រុកខ្មែរចាស់ មានបដិមាករជាច្រើន និងចារឹកផ្សេងៗ បញ្ជាក់ឲ្យឃើញថាសាសនានេះ មានប្រើចូលបែបសាសនាដែលនៅជិតគ្នា ដែលលោកហាមីដារមេស្តីទេវ និយាយថាមានចារឹកសំស្ក្រឹតខ្លះ រំលឹកដល់ព្រះឥសូរក្នុងបទដើម ហើយដល់ព្រះពុទ្ធក្នុងបទបន្ទាប់ អ្នកប្រាជ្ញនៅខាងបូព៌ាប្រទេសបានពិនិត្យឃើញថា បែបនេះ មានច្រើននៅក្នុងស្រុកឥណ្ឌាដែរ កាលក្នុងសករាជជាមួយគ្នា

គេឃើញក្សត្រិយ៍ខ្លះផ្សាយសេចក្ដីអនុគ្រោះ ទៅលើអ្នកកាន់សាសនាព្រះឥសូរនារាយណ៍ ព្រះពុទ្ធឥតមានរើព្រះហឫទ័យទៅពួកណាជាងពួកណាឡើយ ។

ចារឹកនៅអង្គរវត្តដែលពោលខាងលើនេះ បានធ្វើក្នុងឆ្នាំ ៨០០ គឺជាចារឹក ដែលធ្វើក្រោយបំផុតក្នុងមហាសករាជដែលមានមកដល់យើង ។

តពីឆ្នាំ ១៣០០ មក ពង្សាវតារស្រូបបាត់ទៅជាច្រើនរយឆ្នាំ ដែលបាត់នេះគឺដោយគ្មានប្រាសាទដែលមានចារឹកអក្សរ ចុះហេតុអ្វីបានជាបាត់សូន្យ ត្រង់នេះយើងក៏មិនបានប្រាកដ អំពីហេតុដែលនាំឲ្យបោះបង់អង្គរ ដោយជាការគ្មានគេចាំសោះ ប៉ុន្តែប្រហែលតែមកពីកើតចម្បាំង នឹងស្រុកសៀមជាញឹកញយហើយគេលុកលុយបានជាច្រើនគ្រា ទើបស្រុកខ្មែរបោះបង់ទីក្រុងនេះចោល លុះដល់មកឆ្នាំ ១.៦០០ ទើបមានសិលាចារឹកនៅអង្គរជាថ្មីទៀត ក្នុងចារឹកទាំងនេះគ្មានចារឹកណាមួយធ្វើចំពោះទៅសាសនាឥណ្ឌូសោះ ចារិកទាំងអស់មានកិរិយាចំពោះតែទៅពុទ្ធសាសនា ចារឹកទាំងអស់នេះឆ្លាក់នៅលើសសរអង្គរវត្ត សម្ដែងនូវជ័យជម្នះរបស់ពុទ្ធសាសនា ក្នុងប្រាសាទសម្រាប់សាសនាព្រាហ្មណ៍ដែលមានពុទ្ធរូបទឹបមាសជាជំនួសបដិមាករព្រះនារាយណ៍ ចារឹកទាំងនេះមានសេចក្ដីដើមជាភាសាបាលីជាច្រើន គឺជាជ័យជម្នះពុទ្ធសាសនា ក្នុងកោះលង្កា លើសាសនាចាស់ក្នុងស្រុកខ្មែរ ។

នៅវេលាដែលបានរៀនវិជ្ជាក្នុងស្រុកឥណ្ឌាទៅ គេបានដឹងអំពីរឿងការចិន ដែលមានប្រយោជន៍យ៉ាងធំក្នុងវិជ្ជាតាំងនេះ គឺសុទ្ធតែជាពួកអ្នកដំណើរជាតិចិនទាំងអស់ដែលធ្វើឲ្យយើងដឹងអំពីស្រុកឥណ្ឌា កាលដើមគ្រិស្តសករាជ ហើយអ្នកដែលរិះរកវិជ្ជាឥណ្ឌានោះ ត្រូវការដល់ចារឹកហ្វា-ហៀនទិងហៀនត្សង់ជាញឹកញយ ចំណែកខាងពង្សាវតារស្រុកខ្មែរនេះទៀត ក៏ស្រុកចិនធ្វើឲ្យយើងបានដឹងដែរ គឺមានសេចក្ដីពណ៌នាខ្លួន បរិ-បូណ៌អំពីស្រុកខ្មែរក្នុងកាលដែលចំរើនរុងរឿង ។

ក្នុងឆ្នាំ ១៨១៩ លោកអាបិលរេមុយសាត បានប្រែពីភាសាចិនមកជាភាសាបារាំងសែស សៀវភៅ១ដែលជាវគាគួន ជាកដទូតស្ដេចកូ-ប៊ីឡាយខ័នបានតែង អ្នកដំណើរនោះស្ដេចចិនបានចាត់មកឯនគរចិនឡាក្នុងវេលាដុតឆ្នាំ ១៣០០ ឯសេចក្ដីដែលតែងនេះ លោកប៉ូលប៉ិលីយ៉ូបានប្រែជាថ្មីទៀត(១) ហើយឃើញមានជាច្រើនទំព័រដែលសាស័ព្ទអំពីអង្គរ ។

កាលក្នុងជាន់លោកអាបិលរេមុយសាតនោះ គ្មាននរណា១ ជឿថាប្រាសាទដែលជាវគាគួនបានឃើញនោះ គង់ទ្រង់នៅដរាបដល់សព្វថ្ងៃនេះឡើយ លុះតែសំបុត្រនឹងសេចក្ដីកត់សម្គាល់របស់លោកហង់រីមូហុតបានផ្សាយក្នុងលោកឡើង អំពីដែលបានឃើញប្រាសាទបុរាណទាំងនេះទើបចារឹករបស់ជាវគាគួននេះមានគេត្រូវការឡើងដែរ គួរឲ្យពេសព្វសា-ធុការឲ្យបានសេចក្ដីដែលលោកប៉ូលប៉ិសីយ៉ូប្រែនោះ ពោះពុម្ពឡើងជា

(១) មានក្នុងប៉ុស្តិ៍តាំងសាលាបារាំងសែសនៅចុងស្រុកបូព៌ាប្រទេស ខ្សែ ២ ។

សៀវភៅហើយសៀវភៅនេះនឹងមានអ្នកដែលមើលនោះជាច្រើន ៗ

ជាវតាគួននេះជាអ្នកណែផ្លូវ ១ ដ៏មានតម្លៃ គាត់បានយកចិត្តទុកដាក់ឲ្យចេះដឹងការទាំងអស់ តាំងពីការតូចតាចបន្ទាប់បន្សំដែលអ្នកដំណើរជាតិជាមួយនឹងគាត់តែងពណ៌នា គ្មានរបស់អ្វីរួចពីភ្នែកគាត់ឡើយ សេចក្តីដែលគាត់តែងតាំង ៤០ ចំពូកនោះ មាននិយាយអំពីបែបបកងទ្រង់ទ្រាយស្រុក អំពីផ្លូវក្នុងស្រុក ទំនៀមទម្លាប់របស់អ្នកស្រុក របរក្សេត្រាធិការ និងផលដែលកើតក្នុងស្រុក គាត់បានពិនិត្យឃើញថា ស្រុកនោះនៅស្រួលណាស់ ព្រោះស្រួលរកស្រូវអង្ករ ស្រួលរកភរិយា ស្រួលធ្វើរបរពាណិជ្ជការ អំពីផ្ទះសម្បែងនោះគាត់បានអធិប្បាយដោយផ្ចិតផ្ចង់ គឺផ្ទះរាជការសុទ្ធតែប្រក់សំណរសង្កសី ឯផ្ទះឯទៀតប្រក់ក្បឿងដីដុត ហើយឯផ្ទះបណ្តារាស្ត្រវិញនោះសុទ្ធតែប្រក់ស្បូវទាំងអស់ ក្នុងកន្លែងសម្រាប់ធ្វើសន្និបាតនោះបង្អួចធ្វើពីមាសទាំងអស់ នៅជញ្ជាំងមានឆ្លាក់ជារូបដំរីហើយគេឃើញមានកញ្ចក់រៀបរៀងជាជួរ អ្នកដំណើរនេះសាសព្ទតទៅទៀតថា នៅក្នុងវាំងមានប្រាសាទកំពូលខ្ពស់ ១ នៅខាងលើប្រាសាទ កំពូលខ្ពស់នោះ មហាក្សត្រិយ៍តែងផ្ទំនៅ អ្នកស្រុកទាំងអស់និយាយថា ក្នុងប្រាសាទនោះមានព្រលឹងពស់ ១ មានក្បាល ៩ ជាម្ចាស់ផែនដី ថាព្រលឹងនោះនិម្មិតជារូបស្ត្រី ១ រាល់យប់ ហើយស្តេចតែងតែទៅផ្ទំជាមួយជាដំបូង បើទោះជាអគ្គមហេសីស្តេចទី ១ ក៏មិនហ៊ានចូលទៅក្នុងទីនោះដែរ លុះយាមទី ២ ទើបស្តេចចេញពីក្នុងបន្ទប់នោះទៅ

ផ្ទុំនឹងអគ្គមហេសី ឬស្រ្តីជាបរិវារឯទៀតបាន បើយប់ណា ១ មិនឃើញព្រលឹងពស់នេះមក នោះកំណត់ព្រះជន្មស្តេចអយ់ត្រឹមនោះឯង បើស្តេចខានមិនបានទៅផ្ទុំនឹងពស់នោះ ១ យប់នោះនឹងមានកើតចលាចលអ្វីមិនខាន រឿងដែលអ្នកដំណើរចិនអធិប្បាយនេះ មិនទាន់លប់ពីខួរក្បាលជាតិខ្មែរនៅឡើយ ហើយសព្វថ្ងៃនេះ នៅក្នុងភូមិខ្លះ ក្នុងនគរខ្មែរនៅមានរៀបពិធីថ្វាយដល់ព្រលឹងនាងនាគី ដែលជាមាតារបស់នគរនោះៗ

ឯចំពូកក្រោយបង្អស់ ក្នុងសៀវភៅដែលជាវតាគួនតែងនោះមានសារបានថា អំពីស្តេចយាងចេញ ជាវតាគួនបាននៅក្នុងតំបន់អង្គរជាង ១ ឆ្នាំ ហើយបានឃើញស្តេចយាងចេញបួនប្រាំដង គាត់បានអធិប្បាយជួនបរិបូណ៌ អំពីរបៀបក្បួនដែលហែលជាដូចនេះ មានសេនាសេះនៅពីខាងមុខក្បួន ហើយខាងក្រោយបន្ទាប់មានទង់ជ័យតូច-ធំ និងតូរ្យតន្ត្រី ស្រ្តីក្នុងវាំងបានចំនួន ៣០០ ទៅ ៤០០ នាក់ ប្រដាប់ដោយសម្លត់មានគំនូជាដើមឈើមែកឈើ មានផ្កាសៀតត្រចៀកកាន់បន្ទុះគ្រប់ៗដៃ ដើរជាជួរគ្នាដោយពួកៗ ទោះជាកណ្តាលថ្ងៃក្តី បន្ទុះទាំងឡាយនោះអុជឲ្យឆេះជានិច្ច រួចពីនោះទើបមានស្រ្តីក្នុងវាំង ដែលកាន់គ្រឿងប្រដាប់ស្តេច ពីមាសនិងប្រាក់និងគ្រឿងអលង្ការផ្សេងៗ មានបែបទីទៃពីគ្នា ហើយដែលខ្ញុំមិនអាចនឹងដឹងថាគេប្រើប្រាស់ដូចម្តេច តពីនោះទៅទៀត មានស្រ្តីក្នុងវាំងកាន់លំពែងនិងខែល ស្រ្តីទាំងនោះសុទ្ធតែជាសេនាអមផ្ទាល់អង្គរបស់ស្តេច ទើបមានរទេះរបនាទៅដោយ

មាស ទឹមពពែនិងទឹមសេះបរតាមពីក្រោយ សេនាបតីនិងព្រះរាជវង្សានុវង្សទាំងឡាយ ជិះដំរីទាំងអស់ដើរទៅខាងមុខហោលក្អែកត្តោះទៅកាន់ទីឆ្ងាយ ឯក្លោះទាំងឡាយដែលបើកបាំងសេនាបតីនិងព្រះរាជវង្សានុវង្សនោះ មានចំនួននិងគណនាពុំបាន ក្រោយពួកទាំងនេះមានមហេសីនិងបរិវារស្តេច ជិះរ៉េ ជិះរទេះ ជិះដំរីរៀងគ្នាទៅ មានក្លស់ប្រហែលជាង ១០០ បេនាដោយមាសបើកបាំង នៅក្រោយស្ត្រីទាំងនេះ គឺស្តេចឈរលើដំរី ហើយព្រះហស្តទ្រង់ព្រះខ័នដ៏វិចិត្រ(១) អស់ទាំងក្លកដំរីសុទ្ធតែបង់បង្កំមាស មានក្លស់ចំនួនជាងម្ភៃមានពណ៌សរបេនាដោយមាសបើកបាំងថ្វាយ ឯដងក្លស់ទាំងនេះសុទ្ធតែធ្វើពីមាសទាំងអស់ មានដំរីជាច្រើនប្របៀតគ្នាជុំវិញស្តេច មានសេនាសេះ ១ ពួកកំងរដំរីទាំងនេះ មិនឲ្យជិតស្តេច បើស្តេចទ្រង់យាងទៅកាន់កន្លែងដែលនៅជិតៗនោះ ទ្រង់គង់លើរមានស្ត្រីក្នុងវាំង ៤ នាក់សែងទៅ ។

នៅវេលាដែលមើលសេចក្តីទាំងនេះ ហើយនរណា១ដែលមិនគិតដល់រឿងដែលមានជាប់នៅជញ្ជាំងអង្គរវត្តនោះ មានរឿង១ដែលឆ្លាក់នៅជញ្ជាំងប្រវែងប្រហែលជាង១០០ម៉ែត្រ រឿងនោះអ្នកដំណើរទាំងអស់បានស្គាល់ថាជារឿងលើកទ័ព(២) រូបនេះឆ្លាក់នៅក្រោមក្បាច់ស្លឹកឈើ ដែល

១- ព្រះខ័នដែលមាននៅក្នុងវាំងនៅក្រុងភ្នំពេញនោះប្រាកដជាព្រះខ័នរាជស្តេចខ្មែរកាលពីដើមហើយ ។ ២- ចម្លាក់នៅជញ្ជាំងអង្គរវត្តនោះ អ្នកដំណើរជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះដុកទ័របាស្សង់ដែលបានមកមើលអង្គរបានតែង ហើយវាយសេចក្តីជាដំបូង នៅវេលាក្រោយដែលលោកមូហុតបានរកឃើញ ការនេះលោកសឺដេសបានចាប់ធ្វើតទៅទៀត បា. ពិនិត្យទៅឃើញមានរឿងជាច្រើនដែលធ្វើតាមរឿងរាមាយណ ។

របនាដោយផ្តិតផ្តង់ ជាតំណាងរាំងស្តេច ១ និងកងទ័ពកំពុងដើរ ១ កង មានរូបស្តេចឈរនៅលើដំរី ហើយឆ្ពោះព្រះភក្ត្រទៅកាន់ទីឆ្ងាយ ដូចជាកាលដែលជៅតាគួនគាត់បានពិនិត្យមែន មានសេនាសេះជិះលើខ្នងសេះ អស់ពាំងពាហនឈរជាជួរអណ្តាប់គ្នាដូចជារបង មានព្រាហ្មណ៍កាន់ភ្លើងជ័យ មានស្តេចស្ត្រីគង់លើអង្រឹងមានពួកមហោស្រពពាក់មកុដស្រួចហើយមានផ្កាព្រាវក្តួខក្មេងនឹងខ្ញុំកញ្ជះ ។ល។ ហើយមានបរិវារដង្ហែមិនបេះផុត មានពណ៌ប្រផេះដូចជាស្រមោល ហើយសម្លៀកបំពាក់នោះគេធ្វើតាមចិត្តទឹក ធ្វើជាពណ៌មាសនឹងជាពណ៌ក្រហមឆេះ វេលាដែលនិយាយដល់មកកងទ័ពនេះ យើងក៏គិតដល់ទៅកងទ័ពស្តេច ដែលទើបនឹងលើកទៅមុខ ម៉ារេសាល់ស្រុកបារាំង មានប្រគំតន្ត្រីស្គរនិងស្រឡៃខ្មែរ កណ្តាលទីស្ងាត់នៅអង្គរ ។

ជៅតាគួនមិនមែនជាអ្នកអធិប្បាយអំពីស្រុកខ្មែរ តែម្នាក់ឯងទេ ក្នុងពង្សាវតារចិនពួកត្សិនពួកត្សៀងខាងត្បូង និងពួកតាង ក៏មានជាច្រើនចំពូកដែលនិយាយអំពីស្រុកហ៊្វូណន ដែលជាស្រុកខ្មែរចាស់[1]នគរនេះកាលក្នុងដើមគ្រិស្តសករាជថ្កុំថ្កើងបរិបូណ៌ ឯផលដែលកើតក្នុងស្រុកនោះ គឺមាសគ្រឿងក្រអូបនិងត្បូង គេមានឆ្លាក់រូបពីឈើគឺខ្លឹមចន្ទន៍ ពួកអ្នកដំណើរចិនបានសាសព្វទៀតថា ក្នុងស្រុកនេះមានសត្វបចាក និង សត្វ

១- មើលសៀវភៅហ៊្វូណន ដែលមោនសៀប៉ុលីយូបានតែង នៅក្នុងប៊ុល្លីតាំងសាលាបារាំងសែស នៅចុងបូព៌ាប្រទេស ខ្សែ ៣ ឆ្នាំ ១៩០៣ ។

សេកជាច្រើន ។

ដោយជាប់ស្ពានមេត្រីនឹងស្តេចស្រុកចិនជាមាំមួន នោះស្តេចស្រុកហ្វ៊ូណានបានតាក់កងទូតនាំសួយសារអាករទៅថ្វាយ ស្តេចស្រុកចិនជាញឹកញយ ឯសួយសារទាំងនោះសុទ្ធតែជាផលដែលមានក្នុងស្រុក ជួនកាលជាដំរី ឯសត្វនេះដោយព្រោះរូបរាងប្លែកពីគេ ក៏ស្រុកចិនគេថាសត្វឧត្បាតចង្រៃទើបក្នុងកាលនោះមានព្រះរាជប្រកាសស្តេចស្រុកចិន ហាមមិនឲ្យនាំដំរីចូលទៅ ព្រោះសត្វដែលរូបរាងប្លែកមកពីស្រុកឆ្ងាយនោះអាចនឹងបង្កើតជាមេជំងឺក្នុងនគរបាន ។

(មានតទៅទៀត)

កោសជ្ជ

គឺ សេចក្ដីខ្ជិលប្រអូស

ពាក្យកាព្យរបស់ ថី ឆ. គឹមហាក់ ធ្វើរាជការនៅមន្ទីរ

ប៉ុស្ដិ៍ខ្សែលួស ក្រុងភ្នំពេញ រៀបរៀង

កោសជ្ជ

កោសជ្ជជាភាសាបាលី ប្រែតាមសម្ដីខ្មែរនិម្មល
គឺខ្ជិលប្រអូសក្នុងកាយពល គ្មានគិតរវល់ពីការងារ ៗ
មុននឹងបរិយាយស្រាយរឿងនេះ ខ្ញុំសូមរេរិះក្នុងទ័យា
រំលឹកទឹកគុណព្រះពុទ្ធា ធម្មាសង្ឃាជូនពេកក្រៃ ៗ
រួចខ្ញុំសូមថ្លែងថែងអធិប្បាយ កែស្រាយកាយតាមដោយនិស្ស័យ
ប្រាជ្ញាខុសអាប់ក្រឧបមេយ្យ ដូចពេជ្រពុំថ្លៃអាប់រង្សី ៗ
សូមពួកបណ្ឌិតត្រឹទ្ធាចារ្យ ខមេថទោសអស់សម្ដី
ដែលខ្ញុំពោលហើយពុំគប្បី សេចក្ដីខុសឆ្គងគងពាក្យពិត ៗ
សត្វលោកត្រូវដឹងប្រឹងបង្ការ កុំឲ្យបាបណាឆ្លាមកជិត
ត្រូវខំសង្វាតឧហាតពិត ត្រូវប្រើគំនិតគិតការល្អ ៗ
ដូចជាត្រួបសេចក្ដីខ្ជិល ក្រាលដោយមន្ទិលអធិករណ៍
ជនកបតេជ:តប:បវរ គោងបេះយុទ្ធតកុំឲ្យបៀត ៗ

បើខំត្រែសតបណ្ដែតចិត្ត ខ្ជិលចូលមកជិតតែសិកសៀត
ទុក្ខារើផ្ទួនផ្ទួនមកទៀត ទុកស្ទើរខ្លាតឃ្លាតពីប្រាណ ៗ
ខ្ជិលនាំខូចខាតច្រើនពន្លឹក មហាសន្ធឹកគុណពុំបាន
ជនានុជនកុំរាប់អាន ទើបបានឆ្ងាយឋានពីអប្បលក្ខណ៍ ៗ
ខ្ជិលធ្វើការងារគ្មានធនធាន ខ្ជិលពុំគិតរៀនគ្មានយសសក្តិ
ខ្ជិលរការពារខាតវិស្រាសៈ ខ្ជិលស្ម័គ្រព្រះពុទ្ធគ្មានចេស្ដា ៗ
ខ្ជិលដកដង្ហើមប្រាសជីវិត ខ្ជិលគិតពុំបានថ្លាបញ្ញា
ខ្ជិលនិយាយពុំចេះវោហារ ខ្ជិលដើរយាត្រាខ្វិនពុំខាន ៗ
ខ្ជិលស្ដាប់សព្ទសូរប្រែជាថ្លង់ ខ្ជិលចង់គង់តែនឹងខានបាន
ខ្ជិលធ្វើបុណ្យមានគង់ក្រប្រាណ ខ្ជិលរកកំសាន្តខានសប្បាយ ៗ
ខ្ជិលសូត្ររៀនធម៌ធ្លាក់នរក ខ្ជិលលក់ទំនិញគ្មានលុយចាយ
ខ្ជិលដូតគង្គារគង់ក្រហាយ ខ្ជិលសំអាតកាយគ្មានក្លិនល្អ ៗ
ខ្ជិលថែរក្សាពុំឋិតថេរ ខ្ជិលសរសេរពុំចេះអក្សរ
ខ្ជិលពុំចង់មាននឹងបានក្រ ខ្ជិលល្អគង់តែបានអប្រិយ ៗ
ខ្ជិលមើលបួរទៅគង់ពិលខ្វាក់ ខ្ជិលថ្នាក់ថ្នមថែកក្ដីបេតី
ខ្ជិលពុំការនាគ្មានស្មារតី ខ្ជិលរកខន្តីគ្មានអំណត់ ៗ
ខ្ជិលរៀនក្រមច្បាប់ត្រូវផ្ដូនា ខ្ជិលរកទ្រព្យគង់កំសត់
ខ្ជិលរៀនទន្ទេញពុំចេះគត់ ខ្ជិលប្រត់គង់ភ្លាត់ជួលមិនខាន ៗ

ខ្ជិលរៀនវិន័យត្រូវគាបត្តិ　　ខ្ជិលស្ទាត់ធ្វើម្តេចនឹងជួបប្រាណ
ខ្ជិលបោសជម្រះពុំស្អាតបាន　　ខ្ជិលប្រាណធ្វើម្តេចរលំខ្លួន ៗ
ខ្ជិលចងធ្វើម្តេចនឹងបានជាប់　　ខ្ជិលកប់ធ្វើម្តេចដឹងចំនួន
ខ្ជិលប្រើមេត្តាឆ្ងាយក្តីសួន　　ខ្ជិលពួនធ្វើម្តេចនឹងបានបាត់ ៗ
ខ្ជិលហៅធ្វើម្តេចនឹងស្គាល់នាម　　ខ្ជិលស្រៀមធ្វើម្តេចបានក្តីស្ងាត់
ខ្ជិលដេញធ្វើម្តេចនឹងព្រាត់ខ្ចាត់　　ខ្ជិលណាត់ធ្វើម្តេចត្រូវវេលា ៗ
ខ្ជិលលាងធ្វើម្តេចនឹងបានជ្រះ　　ខ្ជិលធ្វើការហោសខាតកាលា
ខ្ជិលរក្សាសីលកើតរោគ　　ខ្ជិលទារធ្វើម្តេចគេនឹងសង ៗ
ខ្ជិលឲ្យធ្វើម្តេចគេនឹងអរ　　ខ្ជិលតទំនិញខាតទ្រព្យផង
ខ្ជិលចរចាល្អនាំសៅហ្មង　　ខ្ជិលប៉ងម្តេចនឹងដូចប្រាថ្នា ៗ
ខ្ជិលទន្ទេញធ្វើម្តេចបានចាំ　　ខ្ជិលដាំធ្វើម្តេចបានផ្លែផ្កា
ខ្ជិលខាត់ធ្វើម្តេចបានជ្រះថ្លា　　ខ្ជិលស្អប់តណ្ហាទៅអបាយ ៗ
ដូនអើយមើលចុះខ្ជិលទ្រមក់　　នាំកើតកលយុគផងទាំងឡាយ
តែងមករួមរឹតជិតកិតកាយ　　នាំឲ្យអន្តរាយច្រើនពេកក្តាត់ ៗ
ខូចឃើញរបស់ស្រស់សោភា　　អស់ទាំងទ្រព្យាសឹងសោត
វិនាសសាបសូន្យសណ្ឋានខ្ចាត់　　ដូចថ្នល់បាក់ក្នុងគង្គា ៗ
ពុំដែលអណ្តែតត្រសែតឡើង　　ពុំដែលបានថ្កើងមួយវេលា
រមែងស្លូតតូចដូចចង្រៃ　　រះកង់ទៅនាកាលចក្ក ៗ

ជនខ្វិលក្តីក្រក៏មកដល់ ខ្វាយខ្វល់ចិត្តជ្រួលអួលអន់អាក់
ហាក់ដូចលំពែងគ្រវែងធ្លាក់ មកចាក់ត្រូវចំដើមឧរ ។
ហើយដើរលួចប្លន់សន្សំធន ធ្វើបាបមហាជនច្រើនគ្រៀបគ្រា
ធ្វើបញ្ឆោតគ្មានរអា ខ្លះអត់អាហារស្លាប់ក្នុងព្រៃ ។
មានខ្លះធ្វើជាសូមយាចក សូមទានលួចឆក់ជនដទៃ
ពុំមានរអែងក្រែងគេនៃ ពុំមានគិតភ័យខ្លាចរាជការ ។
ខ្លួនកម្លាំងពេញកាយពល ពុំចេះទប់ទល់សៀងដីរ
បានចង់យាមមួយស្លួយដាក់ស្មា ដើរសូមអាហារគេអាស្រ័យ ។
ធ្វើប៉ុកយ៉ាន់នេះពេញជាថោក ចាញ់ប៉ុកក្ងោកបក្សថ្ងៃ
នាំខូចពូជពង្សវង្សាសៃយ ពេញជាចង្រៃក្នុងលោកា ។
គ្រកូលណាមួយមានកូនខ្ជិល វង្សនោះមន្ទិលពុំជ្រះថ្លា
ដូចជាព្រះចន្ទក្នុងហតា រាហ៊ូយកក្រឡាមហាសម្បើម ។
ព្រៀងលានជិតខាងគេនិន្ទា គេប្រជុំគ្នានិយាយដើម
ថាពូជនេះពេញជាពុំថ្លើម ដូចទឹកសន្សើមធ្លាប់វិនាស ។
មនុស្សខ្ជិលតែងធ្វើឲ្យផ្លា អាប់ឱនធាយាពុំឱកាស
ដូចផ្កាលដែលជាប់គ្រឿងប្រាក់មាស នាំកើតទិតៀសគ្រប់ទីឋាន ។
ទន្ទេរនោះឯងដូចផ្កាតា គ្មានក្លិននោះណាពុំគុំផាន
បូរីប្រែពុំកប់អាន ដូចព្រះសូរ្យានាទបង់រស្មី ។

សាសនាបម្រុងក្នុងស្រុកនោះ ពុំបានមានឈ្មោះចេតសិរី
ពាបទទន់អន់អួនសួនឲ្យធាប់ខ្មី ដូចនាងកាកីខាតលាភា ៗ
ខ្ញុំសូមដាស់តឿនក្រើនកុលបុត្រ ដ៏វិសេសសុទ្ធតបជ័យ
ត្រូវខំសម្លាប់កោសជា ដោយវិរិយាគឺឧស្សាហ៍ ៗ
ត្រូវមានស្នេហាការដែលធ្វើ ត្រូវខំអើពើរៀនរចនា
ឲ្យបានឆោមចេតកើតផលា បីដូចមាតាស្នេហ៍គ្រប់ត្រកា ៗ
មិនត្រូវត្រូញត្អូរថាឡើយហត់ ចិត្តត្រូវសង្កត់កល់វេលា
ខិតខំរៀនសូត្រតាមមាគ៌ា ដែលប្រាជ្ញនានាបានត្រេចហើយ ៗ
ត្រជាក់រងាក្ដៅក្ដីណា ត្រូវប្រឹងធ្វើការកុំឲ្យស្បើយ
ខំឲ្យបានដល់យល់កោះត្រើយ ទើបបានក្ដីល្ហើយក្នុងកាយា ៗ
ធម្មជាតិបុប្ផាផ្កាកូឡាប តែងក្រាបលូតចេញពីបន្លា
ដូចជាវត្ថុដ៏ថ្លៃថ្លា កើតពីទុក្ខាកល់ទិវា ៗ
សុខតែងកើតក្រោយទុក្ខជានិច្ច បើសុខសូម្បីលិចកើតភ័យា
គួរកុលបុត្រគ្រប់អង្គា រេករិះគិតពាក្យនេះណា ៗ
គិតទៅទីងយល់ស្គាល់តម្លៃ សុខប្រសើរក្រៃជាងទុក្ខា
បើចង់បានសុខតោងឧស្សាហ៍ រៀនសូត្រធ្វើការរបរទាំងឡាយ ៗ
មិនត្រូវទៅដេកត្រកក្នុងខ្ជិល ត្រូវបេះរមិលមើលនាយអាយ
យល់ការពាក់ព្រ័ះទៅវែងឆ្ងាយ ទើបបានសប្បាយកាយកិរម្យ ៗ

ត្រូវមានពាក្យយាមឲ្យណាស់សា ឧបមាដូចសត្វធ្វើទ្រនំ
កណ្ដៀតូចប្រាណមិនបានធំ ពាំដីមកផ្គុំធ្វើគ្រឹះហា ៗ
តូច ៗ តិច ៗ ប៉ុបផ្ដុំ ជាដំបូកធំខ្ពស់មហិមា
កើតពីពាក្យយាមតាមពណ៌នា គួរជនកុំខំយ៉ាងហ្នឹង ៗ
មិនត្រូវគិតណាយស្ដាយកម្លាំង តោងប្រឹងតតាំងរកទីពឹង
រិះរកវិជ្ជាជាទុនទឹង តោងប្រឹងផ្ចឹងប្រើប្រាជ្ញា ៗ
តោងយល់ថាវិជ្ជាលោកិយ លោកុត្តរក្ដីធំណាស់សា
តម្រិះបេះតិចគេចអួតថា បំណេះអាត្មាឥតនរណាស្មើ ៗ
គិតបែបដូចនេះប្រហែសសល់ ខ្ជិលនឹងមកផ្ដល់ខនដំណើរ
ខូចកិច្ចរៀនតម្រិះប្រសើរ ខានដើរទៅកាន់ភូមិសុខា ៗ
គំនិតគិតនេះដូចកង្កែប ពួនបែបក្នុងទឹកអណ្ដូងណា
សម្គាល់យល់ទីនៃអាត្មា គ្មានវាលផលសាណាស្មើបាន ៗ
ប្រសិនប្រសព្វឃើញសមុទ្រ គង់តែរន្ធត់ស្លុតមិនខាន
កង្កែបគង់គិតគិតភ្ញាក់ប្រាណ មើលឆ្ងាយទីឋានរបស់ខ្លួន ៗ
បើកង្កែបឆ្លាតមានប្រាជ្ញា គង់ទិញប្រាជ្ញាយ៉ាងសមសួន
ចង់បាននាទីដែលធំធ្ងន់ បានខ្លួនហែលលេងជាសុខុម ៗ
ដូចជាកុលបុត្រប្រកបល័ក្ខណ៍ ខំគិតស្វែងស្វាក់ប្រមូលផ្ដុំ
ប្រាជ្ញារករៀនវិជ្ជាធំ ត្រៃសតត្រសុំតាមវេណី ៗ

តាំងពីព្រលឹមទល់ព្រលប់ ខំរៀនពុំឈប់ខំសំកី
ពិនិត្យធម៌អាថ៌ក្នុងគម្ពីរ ទំយាវកីគ្មានសម្រាន្ត ។
ច្រើនរៀនវិន័យបច្ច័យសុខ ដែលព្រះពុទ្ធទុកឲ្យគ្រប់ប្រាណ
ស្គាល់ដឹងអាបត្តិទាំងប៉ុន្មាន ដឹងអស់លាក់បាំងទោសនានា ។
មិនបេះពោលថាអាត្មាចាស់ ឬនៅក្មេងណាស់ក្រែងណានា
មិនគួរខំរៀនវិន័យា នាំឲ្យវេទនាលំបាកកាយ ។
ពីព្រោះវិន័យច្រើនហើយជ្រៅ ក្រយ៉ាងសន្សៅទៅវែងឆ្ងាយ
ហត្ថាខ្ចីសល់កុំខ្វល់ខ្វាយ នឹងកាយក្រសោបឧបតីរ ។
កុលបុត្រណាពោលពាំនោលនេះ ហៅថាពុំចេះល្មមពេញទី
មើលសត្វស្រមោចលើប្រថពី ជាទីគួរគិតពិចារណា ។
ស្រមោចខ្លួនតូច ៗ ពេកសល់ ប្រឹងខំរបល់ពាំអាហារ
ធំ ៗ ជាងខ្លួនបីបួនណា យកទុកប្រើការដល់គ្រាក្រ ។
បើពាំពុំរួចអាហារធំ ស្រមោចកុះកុំគ្នាឈ្មូឆេរ
នាំគ្នាម្នីម្នារត់ស្រុះស្រេ ទទួលអំណរពាំចំណី ។
ដូចពួកកុលបុត្រឧត្តុង្គសក្តិ រៀនអាក់ព្រោះពុំយល់សេចក្តី
ពាក្យក្នុងគម្ពីរបេទបាលី នាំគ្នាឃ្លាតខ្លីប្រឹងវិទិច្ឆ័យ ។
សម្រស់សម្រួលផ្ទៀងពិនិត្យ ការរកពាក្យពិតពាក្យប្រពៃ
យូរទៅគង់យល់ក្តីសន្ទៃ អរុណោទ័យៈពេញក្តីថ្លា ។

តូច ៗ ផុំគ្នាកើតជាធំ ដូចស្បូវត្រាំញ៉ាំធ្វើខ្សែណា
រឿងនេះខ្ញុំធៀបប្រៀបឧបមា សាមគ្គីបណ្ដាកុលបុត្រ ។
ឧស្សាហ៍សង្គ្រោះសន្ដោសគ្នា ខំរៀនវិជ្ជាវិសេសសុទ្ធ
ព្យាយាមមាំមួនជួនទាំងមុត គ្មានពុតខ្ជិលខ្ជិលក្នុងកាយ ។
ប្រទះតម្រិះឧត្តមល្អ បេះបែកបន្តបន្តក់ផ្សាយ
ដូចមេមាន់ល្អប្រឹងកកាយ បានបាយបំបែកបែកកូនស៊ី ។
មិនបេះកំណាញ់ស្ងួជាតិ បានហើយវេចគៀតលាក់វក់វី
មិនគិតឲ្យកើតផលសំគី ដូចដីគ្មានជីអាក្រក់សល់ ។
កំណាញ់កើតពីខ្ជិលធ្វើទាន ជាទីប្រធានទាំផ្ដាច់ផ្ដល់
កុំឲ្យយល់យង់វង់កុសល ដូចខ្វាក់ពុំយល់ស្គាល់លោកា ។
បើខ្លួនកំណាញ់លាក់តម្រិះ មិនឲ្យគេបេះពីអាត្មា
តម្រិះតម្រាយអន្ដកយា ខ្លួនស្លាប់កាលណាឥតសារបាត់ ។
ត្រូវយកតម្រាប់ព្រះសម្ពុទ្ធ ជាគ្រូវិសុទ្ធលើបរិស័ទ
ឃើញធម៌ល្អ ៗ ថវរក្ដាត់ ទេសនាប្រាប់សត្វគ្រប់ ៗ គ្នា ។
ព្រះទ័យមេត្តាសត្វទួទៅ ពុំដែលស្ងៀមនៅ ១ វេលា
ប្រដៅឲ្យខំរៀនធម្មា បច្ច័យសួគ៌និព្វានឆាយ ។
ខ្ញុំប្រែកែពីកោសជៈ ពុំទាន់អស់លក្ខណៈទូលាយ
ឲ្យក្មួយល្អៗបុរាសពណ៌ពាយ សូមផ្ញើសម្ដាយអត់ទោសា ។

រឿងនេះខ្ញុំតែងតាមគំនិត　　ខំគិតរំពឹងនឹងបញ្ញា
ទាបខ្ទង់ពង់ពិតឥតឧបមា　　សូមទានមេត្តាកុំនិន្ទា ៗ
គួរមើលពិគ្រោះអស់ពាក្យនេះ　　បើល្អសូមរិះក្នុងន័យា
កុំឲ្យបាបធម៌កោសជា　　មកធ្វើជាមារពាធាបាន ៗ
បើលះខ្ជិលរួចដូចបំណង　　នេះពេញជាច្បងជនសព្វហ៊ាន
ដូចជាទង់ជ័យអម្បាលមាណ　　លោកសឹងរាប់អានហៅថាល្អ ៗ
មានកេរ្តិ៍មានឈ្មោះមានយសសក្តិ　　មានមាសមានប្រាក់ខ្ញុំកំដរ
ញ៉ាំងតួជញ៉ាំងពង្សវង្សបវរ　　ញ៉ាំងឲ្យនគរមានបុប្ផា ៗ
ញ៉ាំងសាសន៍ព្រះពុទ្ធឲ្យប្រពៃ　　ញ៉ាំងធម៌វិន័យនិងសង្ឃា
សន្តោសប្រោសសត្វកាត់វេរ　　ទុកជាដំណាតទៅអើយ ៗ

សេចក្ដីរាយការ អំពីអ្នកតំណាងខេត្តកំពត

នាំប្រាក់ចំនួន ១.០០០រ មកជូនព្រះរាជបណ្ណាល័យកម្ពុជា

ក្រុមការ ជុំ-មៅ ធ្វើការក្នុងព្រះរាជបណ្ណាល័យ អធិប្បាយ

នៅថ្ងៃ ២៨ ខែយូកាំងឆ្នាំ ១៩២៩ អ្នកតំណាងខេត្តកំពតមានឃុនរក្សាកិច្ចាល ម៉ក់ មេឃុំ ៗ ក្នុងខណ្ឌតានី ជាប្រធាន មួយអន្លើដោយភិក្ខុសង្ឃចំនួន ៣០ អង្គ និងឧបាសកឧបាសិកាចំនួន ២០០ នាក់ បាននាំប្រាក់ចំនួន ១០០០រ មកជូនព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីសុំឲ្យរាជមន្ទីរនេះបោះពុម្ពសៀវភៅចីវរខន្ធកនិងបញ្ចាខន្ធក ចែកជាធម្មទានដល់គ្រប់វត្ត ក្នុងកម្ពុជប្រទេស ។

ក្នុងថ្ងៃនោះឯងព្រះរាជបណ្ណាល័យ បានរៀបចំកន្លែងធំសម្រាប់មើលសៀវភៅ ឲ្យទៅជាកន្លែងទទួលនៃនាក់តំណាងខេត្តទាំងនោះ ។

វេលាម៉ោង ៤ រសៀលអស់លោកកុងវិរិយសេនាបតី អ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យនិងនាហ្មឺនសព្វមុខមន្ត្រីខ្លះ មានសម្ដេចចៅហ្វាវាំងវរវៀងជ័យជាអធិបតី បានអញ្ជើញមកជួបជុំក្នុងទីព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីទាំងទទួលឲ្យពរសព្វសាធុការដល់អ្នក ដែលនាំអំណោយដ៏ប្រសើរនេះមក ហើយដើម្បីនឹងញុំាងសេចក្ដីជ្រះថ្លាក្នុងបុញ្ញកម្មនេះ ឲ្យរឹងតែចម្រើនឡើងទៀត ។

ព្រះសង្ឃទាំង ២ គណៈក្នុងក្រុងភ្នំពេញ ក៏បាននិមន្តមកជាច្រើនអង្គ តាមសេចក្ដីនិមន្តរបស់ក្រសួងសង្ឃការី ។

លុះអ្នកតំណាងខេត្តបានចូលដល់មកជួបជុំ ក្នុងព្រះរាជបណ្ណាល័យហើយ ឃុនរក្សាភិបាលម៉ក់ជាតំណាង ក៏បាននាំប្រាក់ចំនួន ១.០០០៛ តម្កល់លើជើងពានដាក់ចុះលើតុ ១ ចំពោះមុខអស់លោកកុងរ្សុយសេនាបតី និងអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ ក្នុងវេលានោះឯង សម្ដេចចៅហ្វាវាំងវរវៀងជ័យ ក៏បានឲ្យពរសព្ទសាធុការ ដល់អ្នកតំណាងខេត្តទាំងអស់ សូមឲ្យបានប្រកបដោយកុសលរាសី និងគុណសម្បត្តិគ្រប់ប្រការគ្រប់ៗ គ្មានវៀងទៅ ។

លុះចប់ពរសព្ទសាធុការហើយ ឃុនរក្សាភិបាល ម៉ក់ ក៏តាំងសូត្រនូវសុន្ទរកថាដែលជាសេចក្ដីពណ៌នាអំពីសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ចំពោះមុខអស់លោកកុងរ្សុយសេនាបតី អ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ នាហ្មឺនសព្វមុខមន្ត្រីនិងព្រះសង្ឃទាំង ២ គណៈ ដែលជួបជុំក្នុងទីនេះ ថាដូចនេះ ។

សុន្ទរកថារបស់ឃុនរក្សាភិបាលម៉ក់

សូមក្រាបបង្គំទូល សូមក្រាបប្រតិបត្តិទ្រង់ និងលោកឡឺរេស៊ីដង់ស៊ុប៉េរីយើរ និងព្រះបាទម្ចាស់ សូមទ្រង់ជ្រាប សូមបាទជ្រាប ។

ផ្សិតទូលព្រះបង្គំជាខ្ញុំៗ ព្រះបាទម្ចាស់ទាំងអស់គ្នា ព្រមទាំងព្រះភិក្ខុសង្ឃសាមណេរទាំងឡាយក្នុងខេត្តកំពត មានគំនិតយល់ឃើញថា

តាំងពីដូចព្រះករុណាជាអម្ចាស់ជីវិត ព្រមទាំងរាជការប្រតិកត្តូក័ត់ក្នុងក្រុង កម្ពុជាធិបតី ដែលបានជំនុំព្រមទាំងអស់លោកព្រះបាទម្ចាស់ជាកុងវ្រីយ សេនាបតី បានបង្កើតឲ្យមានព្រះរាជបណ្ណាល័យនេះឡើង នោះយើងខ្ញុំ ទាំងអស់គ្នាសឹងមានសេចក្ដីចម្រើនដោយការចេះដឹង ស្គាល់ផ្លូវប្រតិបត្តិ ក្នុងព្រះពុទ្ធសាសនាបានយល់ក្ដីច្បាស់លាស់ជាងអំពីដើមនេះ គឺអាស្រ័យ សៀវភៅបោះពុម្ពជាគម្ពីរព្រះពុទ្ធសាសនានិងសុភាសិតផ្សេង ៗ ដែលជា គុណសម្បត្តិ របស់ព្រះរាជបណ្ណាល័យ ផ្សាយចេញឲ្យអស់យើងបាន រៀនសូត្រ ។ យើងខ្ញុំយល់ឃើញតមកទៀតថា គួរតែយើងមាន សេចក្ដីខ្វល់ខ្វាយជួយឧបត្ថម្ភបំពេញព្រះរាជបណ្ណាល័យ ឲ្យរឹងរឹតតែមាន សេចក្ដីចម្រើនរុងរឿង រីកផ្សាយធំទូលាយឡើងទៀត ប៉ុនអម្បាលយើង រាល់គ្នាចំណាយប្រាក់រាប់រយ រាប់ពាន់ កសាងការកុសល មានសង់វិហារ សាលា កុដិ និងបុណ្យកឋិន បុណ្យបញ្ចុះសីមាជាដើម ម៉េចយើងអាចនាំ គ្នាធ្វើរៀង ៗ មកបាន ព្រោះយើងជឿជាក់ថា ធ្វើរួចហើយនឹងបាន ផលបុណ្យជាកំណប់ទ្រព្យរបស់យើងជាប្រាកដ ។ ក៏ដូចជាព្រះរាជបណ្ណា ល័យ ជាឃ្លាំងសម្បត្តិដ៏ប្រសើរ គឺជាឃ្លាំងគម្ពីរសាស្ត្រាក្បួនច្បាប់ជា កន្លែងលំនៅនៃចំណេះវិជ្ជា ជាសម្រាប់ឥស្សរជន នូវអស់ប្រជាជនទាំង ឡាយក្នុងព្រះនគរ ជារបស់យើង ៗ មិនគួរភ្លេចនឹកមិនឃើញនោះឡើយ យើងគួរតែជួយបំពេញ ដោយការបរិច្ចាគធនធានបន្តិចៗម្នាក់ តាមសម គួរដល់ទ្រព្យសម្បត្តិនឹងសទ្ធារបស់យើង ហើយនាំយកមកដាក់ក្នុងព្រះ

រាជបណ្ណាល័យ ដើម្បីនឹងជួយឲ្យព្រះរាជបណ្ណាល័យកាន់តែមានកម្លាំងរឹងប៉ឹងឡើង នឹងបានបោះពុម្ពសៀវភៅដែលជាគម្ពីរក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា ហើយផ្សាយចេញឲ្យបានចម្រើនថ្កុំថ្កើងដល់អស់យើងរាល់គ្នា ឲ្យបានក្រៃលែងជាងសព្វថ្ងៃនេះឡើងទៀត ។

ព្រោះហេតុដូចមានសេចក្ដីខាងលើនេះ ទូលព្រះបង្គំជាខ្ញុំព្រះបាទម្ចាស់ទាំងអស់គ្នាបានព្រមព្រៀងគ្នាចេញប្រាក់រាល់ខ្លួនបន្តិច ៗ ម្នាក់ដោយសេចក្ដីស្រុះស្រួលបានជាប្រាក់ចំនួន ១.០០០ រៀល នាំយកមកដាក់ក្នុងព្រះរាជបណ្ណាល័យនេះ ដោយលោកឡូរេស៊ីដង់និងលោកចៅហ្វាយខេត្តរបស់យើងខ្ញុំ ក៏មានសេចក្ដីយល់ព្រមជាមួយនឹងអស់យើងខ្ញុំផង ៗ ប្រាក់ចំនួនមួយពាន់រៀលនេះ យើងខ្ញុំសុំឲ្យព្រះរាជបណ្ណាល័យចាត់ចែងបោះពុម្ពជាសៀវភៅ ព្រះវិន័យបព្វជាខន្ធកសម្រាយប្រែចេញពីបាលីវិន័យបិដកសេចក្ដីពិស្ដារឲ្យយើងខ្ញុំ ហើយសុំឲ្យព្រះរាជបណ្ណាល័យ ចែកផ្សាយប្រ-គេនដល់លោកគ្រូចៅអធិការគ្រប់វត្តក្នុងក្រុងកម្ពុជាឲ្យយើងខ្ញុំ ពីព្រោះព្រះវិន័យនេះសព្វថ្ងៃនៅខាតមិនទាន់មានរាល់វត្តនៅឡើយ ៗ តែក្រៃលែងប្រាក់នេះចំនួនតិចនឹងអាចបោះពុម្ពជាសៀវភៅចំនួនច្រើនមិនបាន នោះសុំឲ្យព្រះរាជបណ្ណាល័យជួយបំពេញ ហើយព្រះរាជបណ្ណាល័យចំណាយសៀវភៅដែលលើសអំពីចំនួនត្រូវចែកនោះ ជាប្រយោជន៍សេចក្ដីចម្រើនក្នុងព្រះរាជបណ្ណាល័យចុះ ៗ តែតាមសេចក្ដីពេញចិត្តរបស់យើងខ្ញុំ ១ មានសេចក្ដីបំណងថា បើជាមានទំនងស្រួល គឺថាបើយើងខ្ញុំអស់គ្នាអាចនឹង

រិះរលៃលកបាន នោះយើងខ្ញុំនឹងចេះតែនាំគ្នាតៀតចេញប្រាក់បន្តិចៗ ម្នាក់តាមកម្លាំងធនធាន ដូចទំនងយើងខ្ញុំនាំគ្នាធ្វើក្នុងគ្រានេះ តរៀងៗ ទៅទៀត ជាធម្មទានទុកជាកំណប់ទ្រព្យដ៏ប្រសើររបស់យើងខ្ញុំទាំងអស់គ្នា ។

សូមទេវតាទាំងឡាយ ទទួលអនុមោទនាត្រេកអរ ចំពោះផលនិសង្សនៃធម្មទានរបស់យើងខ្ញុំនេះ ។

ដោយអានុភាពនៃធម្មទាននេះ សូមឲ្យមហានគរបារាំងសែសមានសេចក្តីចម្រើន ។

សូមឲ្យព្រះនគរក្រុងកម្ពុជាធិបតីមានសេចក្តីចម្រើនៗ សព្វៗ កាលទៅហោង ។

លុះសូត្រចប់វេលាណា សម្តេចចៅហ្វាវាំងវរវៀងជ័យ ក៏ថ្លែងសេចក្តីអំណរតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងលោកឡឺរេស៊ីដង្ត ស៊ុបេរីយ៉ើរ សរសើរនូវបុញ្ញកម្មនេះថាជាអំពើដ៏វិសេសថ្លៃថ្លា នឹងបានជាតម្រាប់ដំបូន្មានដល់ជនទាំងឡាយក្នុងកម្ពុជរដ្ឋ ព្រមទាំងសរសើរអំពីសេចក្តីយល់ត្រូវរបស់ឃុនរក្សាភិបាលម៉ក់ដែលជាមេគិតផ្តើមឡើង ដោយចេតនាជាញាណសម្បយុត្ត អាចញុំាងមិត្រភក្តិទាំងប៉ុន្មានក្នុងខេត្តកំពតឲ្យយល់ត្រូវតាម ហើយចូលជួយដោយភាគតិចច្រើនតាមកម្លាំងធនធានបានជាសាច់ប្រាក់ ១.០០០៛ នេះ យកមកជួយកម្លាំងព្រះរាជបណ្ណាល័យកម្ពុជា ឲ្យបានរឹតតែរឹងប៉ឹងឡើង សរសើរអំពីសៀវភៅចីរក្ខទក និង

បព្វជាខន្ទក ដែលសុំឲ្យព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ ជាសៀវភៅដ៏មានប្រយោជន៍ក្រៃលែងក្នុងព្រះពុទ្ធសាសនា ព្រោះជាក្រិត្យវិន័យរបស់ភិក្ខុសាមណេរ ដែលមានក្នុងព្រះវិន័យបិដកទាងមូល គឺជាច្បាប់ដែលអាចញុំាងអ្នកបួសឲ្យស្គាល់ខុសត្រូវក្នុងការប្រើប្រាស់នូវត្រៃចីវរ និងបព្វជាក្នុងព្រះពុទ្ធសាសនា ដោយហេតុថា បើបព្វជិតទាំងឡាយទ្រទ្រង់ព្រះវិន័យដោយហ្មត់ចត់ដរាបណា រីព្រះពុទ្ធសាសនាក៏អាចចម្រើនថ្កុំថ្កើងឋិតថេរទៅដរាបនោះ ។

លុះសម្តេចចៅហ្វា បានថ្លែងសេចក្តីសរសើរនូវបុញ្ញកម្មនេះ ជាស្រេចហើយ ព្រះសង្ឃទាំង ២ គណៈ ដែលបាននិមន្តមកជួបជុំក្នុងទីនោះក៏តាំងសូត្រជយន្តោដែលជាធម៌ចម្រើននូវជ័យមង្គល ព្រម ៗ គ្រប់ព្រះអង្គក្នុងវេលានោះ ជាទីញុំាងបណ្តាជនប្រុសស្រីទាំងប៉ុន្មានឲ្យសម្រេចចិត្តជ្រះថ្លាក្នុងបុញ្ញកម្មនេះដ៏ក្រៃលែង លុះចប់ធម៌វេលាណា ទាំងអស់គ្នាក៏លើកដៃប្រណម្យឡើង ទទួលអនុមោទនាថា សាធុ ព្រម ៗ គ្នាក្នុងវេលានោះ ។

ស្រេចហើយ ទើបអស់លោកកុងស៊ុយសេនាបតី និងនាហ្មឺនសព្វមុខមន្ត្រី អញ្ជើញត្រឡប់ទៅតាមផ្លូវទីទៃ មួយអន្លើដោយព្រះសង្ឃនិងបណ្តាជនប្រុសស្រីទាំងប៉ុន្មាន ដែលបាននិមន្ត បានអញ្ជើញមកកាន់ទីបុណ្យនោះ ។

ការកុសលរបស់អ្នកតំណាងខេត្តកំពត ដែលមានឃុនរក្សាភិបាល

ម៉ក់ជាអធិបតី មិនទាន់អស់តែត្រឹមនេះនៅឡើយទេ នៅមានការកុសលម្យ៉ាងទៀត ដែលមិនមែនមានផលតិចច្រើនជាងគ្នាប៉ុន្មាន ហើយដែលខ្ញុំត្រូវការយកមកនិយាយរៀបរាប់ជា ១ គ្នាផង ព្រោះការកុសលនេះឯងជាប់គ្នាពីការដែលទើបនឹងពោលហើយនេះ ខុសគ្នាតែការដែលពោលហើយ គឺនាំនូវហិរញ្ញវត្ថុ មកតម្កល់ក្នុងព្រះរាជបណ្ណាល័យនាក្រុងភ្នំពេញ ហើយឯបុញ្ញកម្មដែលខ្ញុំនឹងអធិប្បាយតទៅនេះ គឺនាំយកសៀវភៅព្រះត្រៃបិដកជាអក្សរសៀម និងព្រះសារីរិកធាតុតម្កល់ដោយព្រះស្តូបមាស និងប្រាក់ពីក្រុងភ្នំពេញទៅតម្កល់ទុក ជាចារឹកព្រះពុទ្ធសាសនាក្នុងវត្តប្រាសាទ ឃុំភ្នំកុង ស្រុកតាទី ខេត្តកំពតវិញ ។

ឃុនរក្សាភិបាលម៉ក់ដែលជាមនុស្សចំណាន ១ ខាងធ្វើការជាកុសល បានផ្តើមធ្វើបុញ្ញកម្មលើកទី ២ នេះយូរមកហើយ គឺបានជាវសៀវភៅព្រះត្រៃបិដក (ព្រះសូត្រ, ព្រះវិន័យ, ព្រះអភិធម្ម) ១ ចប់ ចំនួន ៤៥ សៀវភៅនឹងទូឈើ ១ ជាយូរហើយ យកមកផ្ញើទុកនៅក្រុងភ្នំពេញ នាទីកុដិលោកព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ គាបារក្នុងព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីចាំបានឱកាសដែលនឹងនាំហិរញ្ញវត្ថុមកជូនព្រះរាជបណ្ណាល័យ នឹងដង្ហែយកទៅតម្កល់ទុកក្នុងវត្តប្រាសាទ ដើម្បីសម្រួលដល់ការសិក្សារបស់ភិក្ខុសាមណេរដែលជាអ្នករៀនសូត្រ រីឯព្រះសារីរិកធាតុដែលបានមកជាយូរហើយនោះ ទើបនឹងជួលជាងធ្វើព្រះស្តូបដោយមាស នឹង

ប្រាក់ ដើម្បីតម្កល់ជាទីបូជាគោរព ដង្ហែទៅជាមួយនឹងព្រះត្រៃបិដកនោះ ៗ

លុះបានឱកាសនាំទូវហិរញ្ញវត្ថុមកក្នុងថ្ងៃ ២៤ យ៉ាំងនេះ ក៏តាំងចាប់ផ្ដើមបុញ្ញកម្មលើកទី ២ នេះ នៅវេលាបន្ទាប់តគ្នាពីកាលលើកមុន គឺជាបាននិមន្តព្រះត្រៃបិដកនិងព្រះសារីរិកធាតុមកតម្កល់ជាបណ្ដោះអាសន្នក្នុងទីព្រះរាជបណ្ណាល័យ ហើយវេលាម៉ោង ៧ កន្លះយប់ ក្នុងថ្ងៃជាមួយបាននិមន្តធម្មកថិក ២ អង្គ សម្ដែងធម៌ទេសនា ក្នុងព្រះរាជបណ្ណាល័យកម្ពុជា គឺលោកគ្រូព្រះញាណបរិវិជ្ជា ឯម ចាងហ្វាងសាលាបរិយត្តិជាន់ខ្ពស់ ១ និងលោកព្រះគ្រូសង្ឃវិជ្ជា តាត អាចារ្យបង្រៀនភាសាសំស្រ្កឹតក្នុងសាលាដដែល ១ ក្នុងវេលាដែលរៀបចំសម្ដែងធម៌ទេសនានោះព្រះរាជបណ្ណាល័យដែលជាមន្ទីរដ៏ធំទូលាយ ក្លាយទៅជាមន្ទីរយ៉ាងតូច ១ វិញ ព្រោះក្នុងគ្រានោះមនុស្សដែលត្រូវការស្ដាប់ធម៌ទេសនា ទាំងអ្នកបួសទាំងគ្រហស្ថទៅជួបជុំណែនតាន់តាប់ជ្រៀតមិនចុះ សល់នៅខាងក្រៅជាច្រើន ព្រោះព្រះថេរដែលជាធម្មកថិកទាំង ២ អង្គនេះ សុទ្ធតែល្បីល្បាញចេះចាំនូវធម៌វិន័យយ៉ាងស្ទាត់មុតមាំ ជាទីញ៉ាំងបណ្ដាជនប្រុសស្រីឲ្យចង់ស្ដាប់ ដោយក្រៃលែង អាស្រ័យហេតុនេះហើយ ទើបក្នុងយប់នោះ ឃើញមានមនុស្សដែលចូលមិនចុះ ឈរគន្ធឹយតាន់តាប់នៅខាងក្រៅដញ្ញាំងខ្លះក៏ខំឡើងលើបង្អួចបន្ទឹតឡើងឲ្យតែបានស្ដាប់ ឥតគិតដល់សេចក្ដីនឿយព្រួយ

លំបាកឡើយ ។

ព្រះថេរទាំង ២ អង្គក៏តាំងតាមឆ្លើយនូវអាថ៌ប្រស្នាផ្សេង ៗ យ៉ាងក្បោះក្បាយកណ្ដាលមហាសន្និបាត ដើម្បីកម្ចាត់នូវវិមុតិសង្ស័យនៃមហាជនទាំងឡាយ ដែលអង្គុយប្រណម្យតាំស្ដាប់ដោយស្ងាត់ជ្រៀប ឥតមានប្រែប្រួលធ្វេសស្ដាំ ប្រុងស្មារតីត្រងត្រាប់នូវសព្រះសទ្ធម្មទេសនាតែរៀងខ្លួន លុះដល់ម៉ោង១២អធ្រាត្រ ព្រះធម្មកថិកទាំង ២ ព្រះអង្គក៏បង្ហើបនូវធម៌ទេសនាព្រោះសមគួរដល់កាលវេលាតែប៉ុណ្ណោះ ទឹងទ្រទ្រាំតទៅទៀតមិនបាន រីឯអ្នកស្ដាប់ទាំងអស់គ្នា ស្ទើរតែមិនចង់ក្រោកចេញក្នុងវេលានោះ ព្រោះមានសេចក្ដីស្ដាយដោយស្ដាប់មិនទាន់ឆ្អែត ។

កាលណាព្រះភិក្ខុសាមណេរ និងបណ្ដាជនប្រុសស្រីវិលត្រឡប់ទៅលំនៅវិញទាំង ៗ គ្រប់រូបហើយ បានតាត់ការរៀបចំព្រះរាជបណ្ណាល័យ ដើម្បីឲ្យអ្នកតំណាងខេត្តកំពតសំណាក់ក្នុងរាត្រីនោះ គឺបានរៀបបន្ទប់ខាងជើងសម្រាប់លោកសង្ឃ ហើយបន្ទប់ធំដែលជាកន្លែងទេសនាសម្រាប់ឧបាសកឧបាសិកា ចាំព្រឹកឡើងវេលាណាទឹងត្រឡប់វិលទៅក្នុងខេត្តកំពតវិញ ។

លុះព្រឹកស្អែកឡើងនាថ្ងៃ ២៩ យូវ៉ាំង ឆ្នាំ ១៩២៩ វេលាម៉ោង ៧ អ្នកតំណាងខេត្តក៏តាំងរៀបចំនិមន្តព្រះត្រៃបិដកដែលដាក់ក្នុងទូ យកទៅតម្កល់ក្នុងរថយន្តមួយអន្ទើទីងព្រះស្តូបដែលតម្កល់ព្រះសារីរិកធាតុ ស្រេច

ហើយរថយន្តក៏បរតាមផ្លូវសំដៅឆ្ពោះកាន់ឃុំក្នុំកុង ស្រុកតាទី ក្នុងគ្រានោះឯង ដើម្បីនឹងដង្ហែចូលក្នុងវត្តប្រាសាទ នៅវេលាម៉ោង ៣ រសៀលក្នុងទិវានោះ ។

ឯអ្នកស្រីក្រមុំការបុីឡែស ដែលជាបណ្ណារក្សនៃព្រះរាជបណ្ណាល័យកម្ពុជា ក៏បានអញ្ជើញទៅកាន់បុណ្យនោះដែរ ដោយឃុនរក្សាភិបាលម៉ក់ និងអ្នកតំណាងខែត្រកំពតទាំងអស់គ្នាបានសូមឲ្យអញ្ជើញទៅ តែបានចេញពីភ្នំពេញក្នុងពេលក្រោយ គឺម៉ោង ១១ កន្លះថ្ងៃជាមួយ ។

យើងមានសេចក្ដីសង្ឃឹមថា របៀបបុណ្យដែលរៀបចំដង្ហែចូលក្នុងវត្តប្រាសាទនោះនឹងចំរើនរុងរឿងល្អ គួរជាទីជ្រះថ្លាដល់ម្ចាស់ទានពន់ពេកណាស់ ហើយនឹងបានជាទីស្ងើចនិងជាតម្រាប់ដល់មនុស្សជាតិប្រុសស្រីដែលមិនទាន់បានធ្វើនូវបុញ្ញកម្មនេះ ។

ទីបំផុតនេះ យើងសូមបួងសួងអស់ទេពនិករទាំង ១ ហ្មឺនលោកធាតុដែលមានញាណទិព្វសូមឲ្យពរសព្ទសាធុការនិងចម្រុងចម្រើនដល់អ្នកតំណាងខែត្រកំពតទាំងអស់គ្នា មានឃុនរក្សាភិបាលម៉ក់ ជាទានិស្សក-ធិបតី ដែលមានសេចក្ដីជ្រះថ្លាដ៏ប្រសើរ បានធ្វើអំពើយ៉ាងវិសេសនេះ ឲ្យបានសេចក្ដីសុខសេចក្ដីចម្រើនគ្រប់ ៗ កាលទៅហោង ។